# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

ឆ្នាំទី ២៥ ខែឧសភា លេខ ៥

ព.ស. ២៤៩៦ – គ.ស. ១៩៥៣

# សេចក្ដីជូនដំណឹងអំពីព្រះត្រៃបិដក

ពុទ្ធសាសនបណ្ឌិត្យ សូមប្រគេននិងជូនដំណឹង ៗ

ដ្បិតពីខែមុន, ពុទ្ធសាសនបណ្ឌិត្យបានប្រគេន-ជូនដំណឹងម្ដងហើយថា សៀវភៅព្រះត្រៃបិដកពីភាគ ៣៧ ដល់ ៤៤ បំរុងនឹងបោះពុម្ពឲ្យហើយក្នុងឆ្នាំ ១៩៥៣ នេះឯង, ឥឡូវ យើងសូមបញ្ជាក់ថា សៀវភៅទាំងនោះ ដែលកំពុងបោះពុម្ពសព្វថ្ងៃ នឹងបោះឲ្យហើយស្រេចបានចេញពីរោងពុម្ពព្រមៗ គ្នា ក្នុងខែ តុលា ឬ វិច្ឆិកា ឆ្នាំ ១៩៥៣ នេះជាកំណត់ ៗ ឯតម្លៃដូចតទៅនេះ:-

| | | | | | | | |
|---|---|---|---|---|---|---|---|
| ភាគ | ៣៧ | ថ្លៃ | ៦១៛.០០ | ភាគ | ៤១ | ថ្លៃ | ១០០៛,០០ |
| " | ៣៨ | " | ៩២,០០ | " | ៤២ | " | ៨៧,០០ |
| " | ៣៩ | " | ៨២,០០ | " | ៤៣ | " | ៧៥,០០ |
| " | ៤០ | " | ៧២,០០ | " | ៤៤ | " | ៧២,០០ |

បូករួម ...... ៦៤១៛. ០០

ដូច្នេះ អស់លោក-អ្នកជាវជាមុនដែលមិនទាន់បានបង់ប្រាក់គ្រប់ចំនួននេះនៅឡើយក្ដី អស់លោក-អ្នក ដែលត្រូវការជាវថ្មីក្ដី សូមអញ្ជើញយកប្រាក់ថ្លៃទាំងនេះទៅបង់ជូនពុទ្ធសាសនបណ្ឌិត្យជាមុនឲ្យស្រេចដោយ<u>រួសរាន់ៗ</u>

(តទៅគ្របខាងក្រោយ)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង


*ផ្នែកសាសនា* — *ទំព័រ*

— ទុល្លភបុគ្គល ២ ពួក .......... ព្រះមហា ប៉ាន់ - ដុន ...... ៣២៣

— កឋិនកថា (តមក) .......... ព្រះមហាឧត្ដមវិជ្ជា កែ - អៀន .. ៣៣១

— មតិកនៃពួកពុទ្ធបរិស័ទ .......... លោក ប៊ូ - ប៊ូ .......... ៣៣៨

*ផ្នែកអក្សរសាស្ត្រ*

— ការបណ្ដុះនិស្ស័យ (តមក) ....... ព្រះមហាឧត្ដមវិជ្ជា ប៊ុង - ប៉ម ... ៣៤៤

— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ - កន .......... ៣៥១

— រឿងអារ័ក្សថ្លែងរឿងម្ដេប្រាំ (តមក) ... លោក រ៉ាយ - ប៊ុក .......... ៣៦២

— រឿងស្លាប់ព្រោះជាតិ (តមក) ....... លោក គង់ — លឹម .......... ៣៦៩

— រឿងប៉ូលនឹងវីរ័ស៊ីនី (តមក) ....... លោក ផេង - ជ្រីវ .......... ៣៧៨

— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ .. ពុទ្ធសាសនបណ្ឌិត្យ ....... ៣៨៤

*កំណត់និងប្រវត្តិការណ៍*

— សុន្ទរកថាបណ្ឌិតម៉ាល៉ាល៉ាសេកេរះថ្លែងក្នុង
សមាជសាកលលើកទី ២ នៃពុទ្ធសាសនា (តមក) ពុទ្ធសាសនបណ្ឌិត្យ... ៣៩២

— បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) ក្រសួងធម្មការ .......... ៣៩៩


---


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages


— Les deux Dullabhapuggala... *Brah Mala Pann-Chun....* 323
— Kathinakatha (suite)........ *Brah Maha Ker-œurn .....* 331
— L'héritage des Bouddhistes .... *M. Bou-Po. . . . . . . . . . .* 338


PARTIE LITTERAIRE


— Education morale (suite).... *Brah maha Pœung - Pam. . . .* 344
— Histoire de SAMKOK (suite).. *Oknha Nou - Kan .......* 351
— Les vingt cinq récits du Mauvais Génie (suite) .......... *M. Ray-Buc . . . . . . . . . . .* 362
— Mort pour la patrie (suite) ... *M. Kong - Lim . . . . . . . . .* 369
— Paul et Virginie (suite) ...... *M. Phéng-Chrieu . ....... .* 378
— Activité de la Commission des Mœurs et Coutumes ........ *Institut Bouddhique . . . . . .* 384


NOTES ET CHRONIQUES


— Discours du Dr. MALALASEKERA au 2e Congrés Mondial Bouddhique (suite). ......... *Institut Bouddhique . . . . . .* 392
— Nomination des nouveaux Chau-Adhikar suite ......... *Ministère des Cultes ......* 399


**Prix d'abonnement annuel comprenant 12 numéros : 192$00**

# ទុល្លភបុគ្គលពីរពួក

## ព្រះមហា ប៉ាន់-ជុន វត្តលង្កា ក្រុងភ្នំពេញ

ទេសនាផ្សាយវិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែបុស្ស ឆ្នាំជូតសំរិទ្ធិស័ក

ព. ស. ២៤៩១ (១៤-១-៤៩)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

រតនត្តយំ វន្ទាមិ

សូមថ្វាយបង្គំនូវប្រជុំបីនៃព្រះរតនៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសេចក្តីគោរព ។

បន្ទាប់អំពីនមស្សការដែលជាសេចក្តីខ្ទីនេះទៅ អាត្មាភាពសូមសំដែងធម្មទេសនា តាមសមគួរដល់កាលវេលា ។

ភោ សាធវោ បពិត្រសាធុសប្បុរសទាំងឡាយ ! ក្នុងឱកាសនេះ អាត្មាភាពសូមសំដែងអំពីបុគ្គលកម្រមានក្នុងលោក ។ ពិតមែនតែក្នុងសកលលោកមានមនុស្សច្រើនកប់ដោយរយលាន ប៉ុន្តែបើនិយាយឲ្យឃើញច្បាស់តាមតម្រាស់នៃព្រះសម្មាសម្ពុទ្ធថា បុគ្គលពីរពួក កម្រមាននៅក្នុងលោក ។

បុគ្គលកម្រពីរពួកនោះគឺ បុព្វការី ១, កតញ្ញូកតវេទី ១ ។ បុគ្គលណាបានទំនុកបម្រុងផ្គង់ផ្តើមគេមុន នាំឲ្យគេបានលូតលាស់ដុះដាលឲ្យបានសេចក្តីសុខ បុគ្គលនោះឈ្មោះថា បុព្វការី ។ បុគ្គលណាបានទទួល

សេចក្ដីទុកបម្រុងនោះ ហើយដឹងគុណមិនភ្លេច តែងនឹករឭកឃើញរឿយ ៗ បានតបឧបការគុណវិញ បុគ្គលនោះឈ្មោះថា កតញ្ញូកតវេទី ៗ បើនិយាយដោយសាធារណៈ តាមតែបុគ្គលណាក៏ដោយដែលបានទំនុកបម្រុងគេ បុគ្គលនោះឈ្មោះថា បុព្វការី; អ្នកដែលដឹងគុណហើយបានតបស្នងសងគុណវិញ ពុំគោះគើយព្រងើយ ហៅថា កតញ្ញូកតវេទី ៗ

បើនិយាយតាមលំអាន ដែលតែងតែមាននោះ គឺ :—

មាតាបិតា ជាបុព្វការីរបស់កូនប្រុសកូនស្រី ព្រោះជាអ្នកបីបាច់ចិញ្ចឹមថែរក្សា ទំនុកបម្រុងធ្នង់ធ្ងើមកូនប្រុសកូនស្រី, កូនប្រុសកូនស្រីណាដឹងគុណហើយ បានតបឧបការគុណចំពោះមាតាបិតា កូនប្រុសស្រីនោះឈ្មោះថា កតញ្ញូកតវេទី ៗ

ព្រះសម្ពុទ្ធ ជាសាស្ដាចារ្យនៃយើង បានប្រកាសពាក្យប្រៀនប្រដៅដ៏ល្អបរិសុទ្ធ ឬដែលបានតែងតាំងគម្ពីរក្បួនច្បាប់ដ៏ត្រឹមត្រូវប្រាប់ប្រយោជន៍ពិត ៗ ទុកឲ្យយើងខាងក្រោយកាន់តាមៗមក អ្នកដែលជឿស្ដាប់តាម បានរៀនសូត្រព្រះបរិយត្តិ កាន់តាមទៅក៏កើតផលប្រយោជន៍ បានជួបប្រទះសេចក្ដីសុខសេចក្ដីចំរើន តាមជាន់តាមថ្នាក់ ដោយសាសនាឬគម្ពីរក្បួនច្បាប់ដ៏ល្អបរិសុទ្ធត្រឹមត្រូវស័ក្ដិសិទ្ធិនោះ ហើយជាអ្នកដឹងគុណបានតបឧបការគុណវិញ អ្នកនោះឈ្មោះថា កតញ្ញូកតវេទី ៗ

គ្រូអាចារ្យ ជាបុព្វការីរបស់សិស្ស ព្រោះជាអ្នកបង្ហាត់បង្រៀនឲ្យមានចំណេះវិជ្ជា, សិស្សដែលដឹងគុណហើយ បានតបស្នងឧបការគុណគ្រូអាចារ្យវិញ ហៅថា កតញ្ញូកតវេទី ។

ព្រះមហាក្សត្រ ជាបុព្វការី របស់ប្រជាជនក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ, ប្រជាជនជាអ្នកមានស្វាមីភក្ដិគោរពព្រះរាជារបស់ខ្លួនដោយយល់ជាក់ថា: ខ្លួនបានសេចក្ដីសុខចំរើន ដោយសារគ្រប់គ្រងផែនដី ដែលមានព្រះមហាក្សត្រជាប្រមុខ ក៏ពេញចិត្តព្រមប្រព្រឹត្តតាមគន្លងច្បាប់សម្រាប់ផែនដី ប្រជាជននោះឈ្មោះថា កតញ្ញូកតវេទី ។

## មាតាបិតា និង បុត្រធីតា

ក្នុងសកលលោកបើរាប់តែចំនួនមនុស្សដែលមានមាតាបិតា និងកូនប្រុស-ស្រីច្រើនជាអនេក មិនមែនក្រទេ ព្រោះមនុស្សក្នុងលោកដែលកើតតៗ គ្នាមកនោះមានច្រើនណាស់ តែដែលកម្រមាននោះគឺមិនសូវមានមាតាបិតា ដែលទំនុកបំរុងសង្គ្រោះបុត្រធីតាឲ្យបានត្រឹមត្រូវតាមបែបបទ ច្រើនតែសើសៗ ខ្វះៗ ត្រូវត្រង់ណោះ ខ្វះត្រង់ណោះ មិនសព្វគ្រប់ ព្រោះហេតុនោះបានជាថាកម្រមានក្នុងលោក ។

ឯបែបបទដែលមាតាបិតាត្រូវទំនុកបំរុងបុត្រធីតានោះមាន៥យ៉ាងគឺ:

១.– ចិញ្ចឹមបីបាច់ថែរក្សា ដោយមិនទំរើសកូនឲ្យធំចិត្ត, ឲ្យឡើងតាំង

កាលណាបើឃើញកូនធ្វើអំពើអាក្រក់ប្រញាប់ប្រញាល់រៀសវាង ហាមឃាត់ការពារពកំង មិនធ្វេសប្រហែសបណ្ដែតបណ្ដោយ ប្រាប់ប្រដៅឲ្យស្គាល់ទោសទុច្ចរិត ឲ្យកូនខាបរអាកង់បាលរួញគំនិតលែងធ្វើអំពើអាក្រក់តទៅទៀត ។

២.- រៀនប្រដៅឲ្យកូនរៀនកាន់សុចរិតប្រព្រឹត្តល្អតាមគន្លងធម៌ ប្រាប់ពន្យល់អំពីផលសុចរិតឲ្យច្បាស់លាស់ឲ្យកូនជឿស្ដាប់ ស៊ប់គំនិតពេញចិត្តស្រឡាញ់ផ្លូវល្អ; បង្ហាត់ឲ្យស៊ប់សាំកង់ផ្លូវសុចរិតតាំងតែពីតូចមក ។

៣: ប្រដៅកូនឲ្យថឹកកង់ការរេះដឹងគឺ: បង្ហាត់កូនឲ្យរៀនកប់, រៀនគិត, រៀនបូក. រៀនបែក, រៀនសង់, រៀនពល់. រៀនថ្លឹង, រៀនពស់, រៀនគេរ, រៀនសួង់ស្មានការជាដើម ឲ្យថឹកតាំងពីតូចមក មិនបណ្ដែតបណ្ដោយឲ្យកូនឆាស់តាំងគំនិតប្រាជ្ញាកង់ការរេះដង់ លុះដល់កូនមានអាយុចំរើនធំល្មមឲ្យរៀនចំណេះវិជ្ជាហើយ បានទំនុកបំរុងកូនឲ្យរៀនសិល្បសាស្ត្រនឹងចំណេះវិជ្ជាផ្សេងៗ តាមសមគួរដល់កាលៈទេសៈ នឹងសម័យនិយមមិនបណ្ដែតបណ្ដោយឲ្យល្ងង់ខ្លៅ; ឲ្យកូនប្រុស-ស្រី រៀនអក្សរឲ្យចេះជាមុន រួចសឹមឲ្យរៀនចំណេះវិជ្ជាផ្សេងៗ តទៅទៀត ។

៤.- ត្រូវរៀបចំឲ្យមានផ្ទះសំបែងសមគួរដល់ពូជពង្សជាតិត្រកូលនឹងទ្រព្យធនជាដើម ត្រូវប្រុងប្រយ័ត្នកំបាត់ការរៀបចំឲ្យហួសហេតុ

ហួសទំនង ប្រយ័ត្នកុំឲ្យដាច់ទ្រព្យធន ដល់ថ្នាក់លក់គេត្រ បញ្ចាំគេត្រ ឬជំពាក់បំណុលគេរុំរោះ ត្រាំត្រងយូរទៅ ត្រូវរៀបចំកូនឲ្យល្មមសមគួរ ដល់ការគួរកុំឲ្យខុសទំនង ។

៥.— គិតលៃលកបំណាយទ្រព្យសម្បត្តិឲ្យរៀនចំណេះវិជ្ជា, ត្រូវទិញគ្រឿងប្រដាប់ឲ្យកូនតុបតែងខ្លួនខ្លះ ឲ្យកូនមានសំលៀកបំពាក់គ្រាន់បើ មិនកំណាញ់ស្វិតស្វាញ ហួសប្រមាណ, កាលវេលាចែកទ្រព្យសម្បត្តិឲ្យ ត្រូវចែកឲ្យហើយ ឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់ កុំទុកឱកាសឲ្យកូនឈ្លោះប្រកែកគ្នាទៅខាងមុខ ។

របៀបបទដែលកូនប្រុស - ស្រីត្រូវគោរពបូជាមាតាបិតាមាន ៤ យ៉ាងគឺ:

១.— ថ្នាក់ថ្នមបំបមចិញ្ចឹមរក្សាមាតាបិតាឲ្យពេញលេញ ឲ្យដូចកាលមាតាបិតាចិញ្ចឹមរក្សាខ្លួន បើបានលើសជាងនោះរឹងរឹតតែប្រសើរណាស់ ។

២.— ធ្វើការងារជំនួសមាតាបិតា មិនគោះគើយសោះអង្គើយបណ្តែតបណ្តោយ ឲ្យមាតាបិតានឿយហត់ដកបដល់ចាស់ជរា ទោះបីខ្លួនមានស្វាមីភរិយា បែកមុខការរបរឃ្លាតចេញពីមាតាបិតាទៅហើយ ក៏ត្រូវតែជួយធ្វើកិច្ចការងារ តាមកាលវេលាម្តងៗ ដែលនឹងខានពុំបាន ។

៣.— តាំងវង្សត្រកូលរបស់មាតាបិតា មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តព្រោះខ្លួន ។

៤. គោរពប្រណិប័តន៍ ឲ្យល្មមមាតាបិតាពេញចិត្តឲ្យទ្រព្យសម្បត្តិ កេរ្តិ៍សម្បាច់, ប្រយ័ត្នរក្សាទ្រព្យកេរ្តិ៍អាករដំណែលដែលមាតាបិតាចែកឲ្យ មិនបំប៉ុចបំប្លាញឲ្យខូចខាតខ្ចាយវិនាសអន្តរាយបាត់បង់អសារឥតការ ។

៥. លុះឥតអំពីមាតាបិតាទៅ ត្រូវលើកសព សក្ការៈ ដោយគោរព យ៉ាងថ្លៃថ្នូរ ធ្វើទក្ខិណានុប្បទានឧទ្ទិសផលបញ្ជូនទៅរឿយៗ ។

មាតាបិតានឹងកូនប្រុស-ស្រីដែលបានបំពេញកិច្ចរបស់ខ្លួនតាមបែបបទ ដូចបានថ្លែងមកខាងលើនេះ ទើបហៅថាបុត្តការី កតញ្ញូកតវេទី ពេញទំត្រឹមត្រូវ ។

## ព្រះសម្ពុទ្ធ នឹង ពុទ្ធសាសនិកជន

ព្រះសម្មាសម្ពុទ្ធជាមនុស្សអស្ចារ្យដែលហៅថា "អច្ឆរិយមនុស្ស, ឬអច្ឆារ្យមនុស្ស" ។ ព្រះអង្គមិនមែនមានរាល់កាលសម័យទេ យូរៗ ទើបមានម្តង ព្រោះហេតុនោះបានជាកម្រមានក្នុងលោក ។ ព្រះសម្ពុទ្ធដែលជាគ្រូដើមរបស់យើង ទ្រង់មានព្រះទ័យពេញប្រៀបដោយសេចក្តីអាណិតអាសូរ ទ្រង់ឲ្យសត្វលោករួចរំដោះចាកទុក្ខ, កាលព្រះអង្គជិតចូលព្រះបរមនិព្វានទ្រង់ខំប្រឹងខ្មៀតប្រទានឱវាទផ្តាំថា "អ្នកទាំងឡាយចូរកុំប្រហែសធ្វេស" ។ ដោយហេតុនេះ យើងជាពុទ្ធបរិស័ទ គួរប្រតិបត្តិកាន់តាមលំអានធម៌វិន័យ ពុទ្ធសាសនាដែលជាផ្លូវនាំយើងឲ្យបានជួបប្រទះសេចក្តីសុខព្រមទាំងសេចក្តីចំរុងចំរើន យើងនឹងបានឈ្មោះថា កតញ្ញូកតវេទី ចំពោះព្រះអង្គ ។

## គ្រូអាចារ្យ នឹង សិស្ស

កុំបាច់និយាយដល់គ្រូអាចារ្យដែលបង្ហាត់បង្រៀនប្រដៅចំណេះវិជ្ជាគ្រប់យ៉ាងពិតៗ សូម្បីតែលោកណាដែលកំពុងតែប្រៀនប្រដៅកូនសិស្ស ឬប្រៀនប្រដៅចំពោះធម៌នឹងច្បាប់ត្រឹមត្រូវ ស័ក្តិសិទ្ធិពិតប្រាកដ ដែលជាពាក្យមានប្រយោជន៍ គួររៀនគួរស្តាប់ យើងបានស្តាប់ពាក្យនោះចាំបាន ហើយយកមកត្រិះរិះប្រតិបត្តិតាមទៅកើតសេចក្តីសុខចំរើន លោកអ្នកនោះឈ្មោះថា បុព្វការីរបស់យើងដែរ, យើងត្រូវដឹងគុណ ហើយតបគុណកុំភ្លេចឲ្យសោះ យើងទើបឈ្មោះថាកតញ្ញូកតវេទី ។

## ព្រះមហាក្សត្រ នឹង ប្រជាជន

ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនីមួយ ៗ ព្រះអង្គជាសម្មតិទេព "ទេពតាដោយសន្មត" ទ្រង់ព្រះនាមថា ព្រះរាជា ព្រោះទ្រង់ប្រកបដោយការសង្គ្រោះប្រជាជនដោយសង្គហធម៌ ៤ យ៉ាង គឺ:

១.- ប្រទានទេយ្យវត្ថុឲ្យ

២.- មានព្រះវាចាគួរចង់ឮចង់ស្តាប់

៣.- ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍

៤.- ទ្រង់តាំងព្រះអង្គស្មើៗ គឺប្រើបុកពាឲ្យល្មមពេញចិត្តប្រជាជន

ទ្រង់តម្រង់ប្រជាជនដោយទសពិធរាជធម៌ សម្រាប់ព្រះរាជាមាន ១០ យ៉ាង គឺ:

១.— ទ្រង់ឲ្យទាន

២.— រក្សាសីល ៥ ជានិច្ច

៣.— បំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេសជាតិ

៤.— មានព្រះទ័យទៀងត្រង់

៥.— មានព្រះកាយទន់ភ្លន់សុភាព

៦.— រក្សាឧបោសថសីលតាមកំណត់កាល

៧.— មិនក្រេវក្រោធធ្វើឲ្យប្រជាជនក្តៅក្រហាយ

៨.— មិនបៀតបៀនអ្នកដទៃ

៩.— មានសេចក្តីអត់ធន់

១០.— មិនបំពានលើធម៌លើច្បាប់ ។

ដោយហេតុនេះទើបទ្រង់ព្រះនាមថា បុត្រការីរបស់ប្រជាជន ។

ប្រជាជនដែលបានសេចក្តីសុខ ដោយសារការគ្រប់គ្រងរបស់ព្រះរាជា, ប្រជាជនកាលបានដឹងយ៉ាងនេះហើយ ត្រូវជាអ្នកដឹងគុណតាំងចិត្តស្មោះត្រង់ចំពោះរាជការផែនដី ជួយយកអាសាផែនដី ដោយស្មោះស្ម័គ្រ មានស្វាមីភក្តិ ចំពោះព្រះរាជា ចំពោះរាជការផែនដី ឥតមានរឹងទទឹងទាស់នូវរាជការ យ៉ាងនេះ ហៅថា កតញ្ញូកតវេទី ។

អាត្មាភាពសំដែងមកអំពីបុគ្គលរកក្រ ២ ពួក ដោយសង្ខេបតាមគួរដល់កាលវេលាខ្ញុំ សន្មតថាចប់តែប៉ុណ្ណេះ ឯវំ ។

សូមសិរីសួស្តីមានដល់អស់ខេមរជនអ្នកស្តាប់គ្រប់ៗ គ្នា ។

---

# កាបិនកថា

*របៀបទេសនា បុច្ឆា-វិសជ្ជនា*

## ព្រះមហាឧត្តមវិជ្ជា កែ-អៀន វីរិយប្បញ្ញោ

*វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង*

## ព្រះទេពសត្ថា ស្បូរ-ហាយ ពិនិត្យកែសម្រួល

(តមក)

---

៥.— សាធុ សាធុ អនុត្តេរៈ ម្នាលអនុត្តេរ! អនុត្តេរសំដែងអំពីអានិសង្ស ៥ ប្រការ របស់ភិក្ខុដែលបានក្រាលកឋិនទឹងអនុមោទនាកឋិននោះពេញហៅត្រឹមត្រូវហើយ ចុះទាយកជាម្ចាស់ទាននោះ តើព្រះអនាវរណញ្ញាណទ្រង់សំដែងថាមានអានិសង្សដូចម្តេចខ្លះ? សូមលោកម្ចាស់វិសជ្ជនាមក ៗ

— ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! កឋិនទាននេះកាលបើសំដែងនូវផលដោយកាលទានសោត ក៏ជាទក្ខិណាទានដ៏បរិបូណ៌មានផលច្រើនទាំងអ្នកបរិច្ចាគ ទឹងអ្នកជួយខ្វល់ខ្វាយសមដូចបរិយាយក្នុងនិគមគាថា សម្តេចព្រះមហាករុណាទ្រង់សំដែងក្នុងកាលទានសូត្រថា កាលេ ទទន្តិ សប្បញ្ញោ វទញ្ញូ វីតមច្ឆរា ប៉ុណ្ណោះជាដើមសេចក្តីថា បុគ្គលទាំងឡាយអ្នកមានប្រាជ្ញា ដឹងនូវពាក្យនៃអ្នកប្រាជ្ញ សន្តានល្អ មានចិត្តកំណាញ់ប្រាសចាកហើយៗ បរិច្ចាគនូវវត្ថុទានផ្សេងៗ តាមសមគួរដោយសភាពអនុគ្រោះនិងបូជា, កាលេន ទិន្នំ អរិយេសុ

ឱជិភូតេសុ តាទិសុ ទាយកអ្នកបរិច្ចាគទានបានឲ្យហើយដោយការចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលលោកឆ្ងាយអំពីកិលេសវិសេសដោយសេចក្ដីប្រតិបត្តិស្លូតត្រង់ ពុំឃ្វេសឃ្វងដោយកាយវាចាចិត្ត សុចរិតប្រព្រឹត្តស្មើ ពុំកម្រើកដោយអំណាចលោកធម៌ទាំង ៨ ប្រការ (១); វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា: ទានជាគ្រឿងចំរើនសម្បត្តិរបស់បណ្ឌិតជននោះៗ ជារបស់បុគ្គលមានចិត្តជ្រះថ្លា ហើយគួរជាទក្ខិណាបរិបូណ៌ដោយវិសេសជាវិបាកសម្បត្តិ, យេ ច តត្ថ អនុមោទន្តិ វេយ្យាវច្ចំ ករោន្តិ វា ជនដំពូកណាដែលពុំមែនជាម្ចាស់ទានគ្រាន់តែជាអ្នកជួយអនុមោទនាត្រេកអរសាទរតាមទានគេនោះក្ដី ឬមួយជនដំពូកណាជួយធ្វើវេយ្យាវច្ចកម្មខ្វល់ខ្វាយ យកកាយទៅបំរើកងការកឋិនទាននោះក្ដី, ន តេន ទក្ខិណា ឱនា ទក្ខិណាទានក៏ពុំមានថយចុះ ព្រោះហេតុនោះ, តេបិ បុញ្ញស្ស ភាគិនោ ជនទាំងឡាយដែលត្រេកអរតាមការជួយធ្វើ ជាអ្នកមានចំណែកបុណ្យដែលបានអនុមោទនាជាបត្តានុមោទនាមយៈនិងវេយ្យាវច្ចមយៈនោះ, តស្មា ទទេ អប្បដិវានចិត្តោ យត្ថ ទិន្នំ មហប្ផលំ ព្រោះហេតុដូច្នោះ សាធុជនជា

---

១ លោកធម៌ ៨ ប្រការគឺ: ១— លាភោ បានលាភ, ២— អលាភោ ឥតលាភ, ៣— យសោ មានយស, ៤— អយសោ ឥតយស, ៥— សុខំ សេចក្ដីសុខ, ៦— ទុក្ខំ សេចក្ដីទុក្ខ, ៧— និន្ទា ការតិះដៀល, ៨— បសំសា សេចក្ដីសរសើរ ។

បណ្ឌិតមិនគប្បីមានចិត្តរួញរាកំណាញ់ គប្បីឲ្យនូវទានចំពោះបដិគ្គាហកៈ ដែលគួរទទួលនូវទេយ្យទាននោះ ។ ទាននោះឯងមានផលានិសង្សជាភិយ្យោភាពក្រៃលែងណាស់, បុញ្ញានិ បរលោកស្មឹំ បតិដ្ឋា ហោន្តិ បាណិនំ បុណ្យជាគ្រឿងចំរើនគួរជាទីពឹងពំនាក់នៃពួកសត្វក្នុងលោកទៅខាងមុខ ។ កឋិនទាននេះ កាលបើសំដែងដោយគុណានិសង្សជាទក្ខិណាទានដ៏បរិបូណ៌សមដូចសេចក្ដីក្នុងនិគមគាថា ក្នុងកាលទានសូត្រ ដោយប្រការដូច្នេះ ។ ខ្ញុំបាទវិសជ្ជនាមកអំពីអានិសង្សនៃកឋិនទាន របស់ទាយកជាម្ចាស់ទាន ដោយសេចក្ដីបង្ខេបប៉ុណ្ណេះ សូមទានជ្រាប ។

៦.– សាធុ សាធុ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកពិរោះណាស់ហើយ ខ្ញុំនឹងសួរតទៅទៀត ។ អើលោកម្ចាស់ ចុះហេតុអ្វីក៏ហៅថាកឋិនទាន? នឹងហៅថា ចីវរទាន វិញពុំបានទេឬ? សូមនិមន្តឆ្លើយពង្រីកសេចក្ដីឲ្យសព្វគ្រប់មកមើល ។

– បពិត្រព្រះមហាថេរ! បានជាហៅថាកឋិនទាននោះ បើនិយាយតាមបាលី ក្នុងខន្ធកវិន័យ ក៏មានអាការនឹងពិធីច្រើនយ៉ាងណាស់ តែសូមសំដែងតែខ្លីៗ ល្មមស្ដាប់ចូលចិត្តបាន, ដែលលោកហៅថាកឋិនទាន ព្រោះទានដើម្បីកឋិន ទាំងផលានិសង្សក៏មានពីរចំណែក គឺ: ទាយកអ្នកបរិច្ចាគនោះ ប្រកបដោយផលានិសង្សជាអសង្ខេយ្យចំណែក ១, ខាងបដិគ្គាហកៈ គឺភិក្ខុអ្នកទទួលសោតក៏ប្រកបដោយអានិសង្ស ៥ ប្រការ

ដូចបានសំដែងមកហើយនោះចំណែក ១ ។ ហេតុនោះ ទាននេះទើប
បាននាមហៅថាកឋិនទាន ដោយទាយកប្រាថ្នានឹងធ្វើទាននេះ មាន
កម្រិតកំណត់ត្រឹម ២៩ ថ្ងៃ ក្នុងមួយឆ្នាំប៉ុណ្ណោះ គឺតាំងពី ១ កើតខែ
អស្សុជ ដរាបទៅដល់ថ្ងៃពេញបូណ៌មីខែកត្តិក ជាបំផុតខែកឋិន, បើ
ផុតអំពី ២៩ ថ្ងៃទៅហើយ ទោះទាយកទាយិកា មានទ្រព្យមានសម្បត្តិ
មានសទ្ធាប៉ុន្មានៗ ក៏មិនអាចធ្វើបានឡើយ ទាននេះទើបថាកឋិនទាន
ជាទានកម្រនឹងធ្វើបាន ។ ចំណែកខាងសង្ឃទានក្តី បាដិបុគ្គលិកទានក្តី
ជាទានមិនមានកាលបរិច្ឆេទកំណត់កាលឡើយ, ស្រេចតែទាយកទាយិកា
មានសទ្ធាជ្រះថ្លា ចង់ធ្វើថ្ងៃណាវេលាណា ក៏ធ្វើបានមិនមានហាមប្រាម
ដូចកឋិនទាននេះឡើយ, កឋិនទាននេះហើយ ជាទក្ខិណាទានប្លែកប
ដោយកម្រិតដោយទៀងទាត់ ទាំងមានផលវិសេសលើសទានទាំងពួង
មួយទៀតកឋិនទាននេះ ជាការកម្រទាំងពីរយ៉ាងគឺទាយកអ្នកធ្វើ បើពុំ
ចៀវឆ្លាសពុំចេះក្នុងការធ្វើ ក៏ទៅជាបាដិបុគ្គលិកទានវិញ ពុំពេញជា
សង្ឃទាន ជាកឋិនទានឡើយ ចំណែកខាងបដិគ្គាហកៈ គឺភិក្ខុអ្នក
ទទួល កាលបើពុំចេះក្នុងកឋិនត្ថារកិច្ច មិនចេះនូវបុព្វកិច្ច ៧ ប្រការមាន
កាត់-ដេរ-គក់-ជ្រលក់ជាដើម មិនចេះអានិសង្សទាំង ៥ ចាំនូវមាតិកា
ទាំង ៨ ក៏មិនអាចដើម្បីធ្វើកឋិនត្ថារកិច្ចនោះបានឡើយ ។ មួយទៀត
ការដែលលោកអ្នកគ្រងមិនឡើងជាកឋិននោះ សំដែងដោយអនត្តាការ

២៤ប្រការ ដែលព្រះបរមសាស្ដាទ្រង់បញ្ញត្តទុកក្នុងកឋិនក្ខន្ធកៈ មានសេចក្ដីពិស្ដារណាស់ ពេលនេះគ្រាន់តែសំដែងពុទ្ធប្បញ្ញត្តិ ខាងទោសនៃត្រៃចីវរកឋិននោះដោយសង្ខេបៗ តាមន័យពុទ្ធប្បញ្ញត្តិថា "សំពត់ចីវរនោះបើពុំត្រូវខាត ខាតមាត្រាគឺធំឬវែងហួសប្រមាណជាងចីវរព្រះសុគត ក៏ក្រាលមិនឡើងជាកឋិន ១, ត្រៃចីវរនោះពុំបានកាត់ជាកន្ទ្រង់តូចធំឲ្យជាបញ្ចខណ្ឌ, សត្តខណ្ឌ ឬជានវខណ្ឌ, ឬក៏ជាឯកាទសខណ្ឌ មិនត្រូវតាមរបៀបក្នុងវិន័យ ក៏ក្រាលមិនឡើងជាកឋិន ១, សំពត់នោះជាយវែងមានផ្កាលតាវល្លិ៍ ឬជាផ្សៃផ្សេងៗ ក៏ក្រាលមិនឡើងជាកឋិន ១, ចីវរនោះគឺគេជ្រលក់ដោយទឹករមៀត ទឹកល័ខព្រហ៊ូតលៀងខ្ចីដូចសំបុរក្តុកជ័រ ឬក្រហមដូចព័ណ៌ស្វាទុំ ឬដកគាំ ឬសខ្មៅ ស្វាយ បៃតង ព្រាលដូចសម្បុរមាស ឬសម្បុរផ្កាថា ក៏ក្រាលមិនឡើងជាកឋិនឡើយ ព្រោះហេតុនោះហើយបានជាកឋិនទាននេះពិបាកធ្វើណាស់ លុះតែអ្នកប្រាជ្ញឈ្លៀវឆ្លាសទើបធ្វើបាន; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាសំដែងមកដោយសង្ខេបៗប៉ុណ្ណេះ សូមទានជ្រាប ។

៧.– ម្នាលអនុត្តេរ! ខ្ញុំជ្រាបហើយ តែខ្ញុំចង់ដឹងថា ឯព័ណ៌ចីវរដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យជ្រលក់ដោយទឹកអម្ចត់នោះតើមានប៉ុន្មានប្រការ គឺអ្វីខ្លះ? ព័ណ៌ជ្រលក់នោះ សំដៅយកព័ណ៌បែបណា ទើបសមគួរដល់សមណសារូប ដែលអាចក្រាលឡើងជាកឋិនបាន?; សូមសំដែងតាមច្បាប់ឲ្យច្បាស់មកមើល ។

- ភន្តេ ថេរៈ បពិត្រព្រះថេរៈដ៏ចំរើន! ឯពណ៌ចីវរនោះព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតទុកក្នុងចីវរក្ខន្ធកៈថាមាន ៦ យ៉ាងដោយពុទ្ធដីកាថា អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនំ ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតទឹកជ្រលក់ ៦ យ៉ាង គឺទឹកជ្រលក់កើតអំពីឫស ១ ទឹកជ្រលក់កើតអំពីដើម ១ ទឹកជ្រលក់កើតអំពីសម្បក ១ ទឹកជ្រលក់កើតអំពីស្លឹក ១ ទឹកជ្រលក់កើតអំពីផ្កា ១ ទឹកជ្រលក់កើតអំពីផ្លែ ១; ទឹកជ្រលក់ទាំង ៦ យ៉ាងនេះ គឺសំដៅយកពណ៌លឿងលាយស្រអាប់ គួរយ៉ាងពណ៌ជ្រលក់ខ្ទឹមខ្ទះច្រើនលើកច្រើនដង បានពណ៌បែបណា ពណ៌បែបនោះ ហៅថាទឹកអម្ពត់ សមគួរដល់សមណសារូប ប្រើប្រាស់ស្លៀកដណ្ដប់បាន, ថាបើចីវរនោះមានពណ៌ខុសនឹងសមណសារូប មានរវៀតអង្កោលព្រហ៊ូតជាដើមដូចបានសំដែងពីមុនមកហើយ គប្បីជ្រលក់ខ្ទឹមខ្ទះសង្កត់ពណ៌នោះបេញទើបគួរក្រាលឡើងជាកឋិន បានដោយត្រឹមត្រូវល្អ ៗ បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាវិសជ្ជនាមក បានសេចក្ដីដូចរៀបរាប់មកដូច្នេះ សូមទានជ្រាប ។

៨.- សាធុ សាធុ ម្នាលអនុគ្គេរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះត្រឹមត្រូវហើយ, ខ្ញុំនឹងលើកប្រស្នាដទៃសួរតទៅទៀត ៗ អើ

លោកម្ចាស់ សំពត់យ៉ាងណាខ្លះ ដែលគួរធ្វើជាកឋិនបាន? សូមវិសជ្ជនា អធិប្បាយមកមើល ៗ

បពិត្រព្រះមហាថេរ! ឯសំពត់គួរធ្វើជាកឋិនបាននោះ, ព្រះភគវន្តមុនី ទ្រង់អនុញ្ញាតសំពត់ ៦ យ៉ាងគឺ ខោមំ សំពត់ដែលធ្វើពីសម្បកឈើ ១ កប្បាសិកំ សំពត់ដែលធ្វើពីប៉ុយកប្បាស ១ កោសេយ្យំ សំពត់ដែលធ្វើពីសូត្រ ១ កម្ពលំ សំពត់ដែលធ្វើពីរោមសត្វ (វៀរលែងតែធ្វើពីសក់មនុស្ស) ១ សាណំ សំពត់ដែលធ្វើពីសម្បកធ្មៃ ១ ភង្គំ សំពត់ដែលធ្វើពីរបស់ទាំង ៥ យ៉ាងខាងដើមនេះ ដែលគេត្បាញចម្រុះលាយគ្នា ដូចយ៉ាងសំពត់សូត្រលាយអំបោះជាដើម ១ សំពត់មានជាតិទាំង ៦ យ៉ាងនេះ ទោះជារបស់ថ្មីសុទ្ធក្តី, ជំនុំក្តី, ចាស់ក្តី, ជាសំពត់បង្សុកូលគឺរើសបានពីគំនរសម្រាមជាដើមក្តី, ជាសំពត់ធ្លាក់តាមរានផ្សារ (សំដៅយករបស់គេចោលមិនបាច់ទិញក្តី, មានពណ៌សក្តី, ពណ៌ខ្មៀវក្តី, ពណ៌ដទៃតែអាចលាងឲ្យជ្រះពណ៌នោះចេញបានក្តី, ហើយជាសំពត់លាតគ្មានផ្ទាទាក់ទងគ្នា ជាសំពត់ល្មមដេរតែត្រឹមស្បង់ ១ ប៉ុណ្ណោះ ក៏គួរធ្វើជាកឋិនបាន; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាបានវិសជ្ជនាមកអំពីសំពត់ដែលធ្វើជាកឋិនទានបាន ដូចសេចក្តីដែលបានសំដែងមកនេះ សូមទានជ្រាប ៗ

(មានត)

# មតិកានៃពួកពុទ្ធបរិស័ទ

## ធម្មទាយាទសូត្រ ក្នុងសុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក

### ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ

ក្រសួងពុទ្ធសាសនបណ្ឌិត្យជាអ្នកប្រែ

---

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ព្រះអង្គបានត្រាស់ហៅភិក្ខុទាំងឡាយមកប្រាប់ថា :—

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរយកធម៌(១) របស់តថាគតជាមត៌ក កុំយកអាមិស(២) ជាមត៌កឡើយ តថាគតមានសេចក្ដីអនុគ្រោះចំពោះអ្នកទាំងឡាយថា ធ្វើម្ដេចហ្ន៎ ពួកសាវ័ករបស់តថាគត គួរយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ! បើអ្នកទាំងឡាយយកអាមិសជាមត៌ក មិនយកធម៌របស់តថាគតជាមត៌កហើយ គង់តែមានអ្នកផងតិះដៀលអ្នកទាំងឡាយដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្ដា សុទ្ធតែយកអាមិសជាមត៌ក មិនយកធម៌ជាមត៌កទេ ។

---

១ ធម៌ជាមត៌កនេះ បានដល់ធម៌ ២ យ៉ាងគឺ និប្បរិយាយធម៌ ធម៌ជាចំណែកខាងលោកុត្តរធម៌ទាំង ៩ មានសោតាបត្តិមគ្គជាដើម ១, បរិយាយធម៌ ធម៌ជាចំណែកខាងរបស់បុគ្គលដែលកំពុងប្រព្រឹត្តធ្វើសីល- សមាធិ - បញ្ញា ឬឈាន - សមាបត្តិ ដើម្បីដល់នូវព្រះនិព្វាន ១ ។

២ អាមិសជាមត៌ក បានដល់អាមិស ២ យ៉ាង គឺ និប្បរិយាយាមិស បានដល់បច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម ១, បរិយាយាមិស បានដល់ទានវិសេស មានអន្នទានជាដើម ១ ។ អដ្ឋកថា ។

ទាំងតថាគត ត្រូវអ្នកផងតិះដៀលដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តា សុទ្ធតែយកអាមិសជាមត៌ក មិនយកធម៌ជាមត៌កឡើយ ។ បើអ្នកទាំងឡាយយកធម៌របស់តថាគតជាមត៌ក មិនយកអាមិសជាមត៌កទេ ក៏ត្រូវមានអ្នកផងតិះដៀលអ្នកទាំងឡាយដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តា សុទ្ធតែយកធម៌ជាមត៌ក មិនមែនយកអាមិសជាមត៌កទេ ។ ទាំងតថាគតក៏ត្រូវមានអ្នកផងតិះដៀលដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តាសុទ្ធតែយកធម៌ជាមត៌ក មិនមែនយកអាមិសជាមត៌កទេ ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។

ម្នាលភិក្ខុទាំងឡាយ! ក្នុងទីនេះ តថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត គប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតរបស់តថាគតនៅសល់ច្រើន ជារបស់គួរចាក់ចោល ។ គ្រានោះ មានភិក្ខុពីររូបមកដល់ កំពុងតែមានសេចក្តីស្រេកឃ្លានគ្របសង្កត់ជាខ្លាំង តថាគតក៏ប្រាប់ភិក្ខុទាំងពីររូបនោះថា តថាគតឈប់ឆាន់ហើយ ឯបិណ្ឌបាតរបស់តថាគតនេះនៅសល់ច្រើន ជារបស់គួរចាក់ចោល បើអ្នកទាំងឡាយចង់ឆាន់ចូរឆាន់ចុះ បើអ្នកទាំងឡាយ មិនចង់ឆាន់ទេ តថាគតនឹងចាក់ចោលក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោល

កន្ទឹកដែលគ្មានសត្វ ឥឡូវនេះ ។ បណ្ដាភិក្ខុទាំងពីររូបនោះភិក្ខុ ១ រូបគិតថា ព្រះដ៏មានព្រះភាគទ្រង់សោយស្រេចហើយ បិណ្ឌបាតរបស់ព្រះដ៏មានព្រះភាគនេះនៅសល់ច្រើន ជារបស់គួរចាក់ចោល បើពួកយើងនឹងមិនឆាន់ទេ ព្រះដ៏មានព្រះភាគនឹងចាក់ចោល កន្ទីគ្មានស្មៅស្រស់ ឬនឹងចាក់ចោលកន្ទឹកដែលគ្មានសត្វឥឡូវនេះ ព្រះអង្គបានត្រាស់ប្រាប់ហើយថា ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ឯបិណ្ឌបាតនេះក៏ជាអាមិសមួយដែរ បើដូច្នោះមានតែអាត្មាអញកុំបរិភោគបិណ្ឌបាតនេះឡើយ នឹងទ្រាំអត់សេចក្ដីស្រេកឃ្លាននេះ ឲ្យអស់មួយយប់មួយថ្ងៃ ។ ភិក្ខុនោះក៏មិនឆាន់បិណ្ឌបាតនោះ ហើយទ្រាំអត់សេចក្ដីស្រេកឃ្លាននោះអស់មួយយប់មួយថ្ងៃ ។ គ្រានោះ ភិក្ខុទីពីរគិតថា ព្រះដ៏មានព្រះភាគទ្រង់សោយស្រេចហើយ ឯបិណ្ឌបាតរបស់ព្រះដ៏មានព្រះភាគនេះ ក៏នៅសល់ច្រើន ជារបស់គួរចាក់ចោល បើពួកយើងមិនឆាន់ទេ ព្រះអង្គនឹងទ្រង់ចាក់ចោល កន្ទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលកន្ទឹកដែលគ្មានសត្វឥឡូវនេះ បើដូច្នោះមានតែអាត្មាអញគួរឆាន់បង្ហាន់បិណ្ឌបាតនេះ ឲ្យបាត់សេចក្ដីស្រេកឃ្លាន នឹងបានប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនេះឯង ។ ភិក្ខុនោះក៏ឆាន់បង្ហាន់បិណ្ឌបាតនោះ បានបន្ទោបង់សេចក្ដីស្រេកឃ្លាន បាត់អស់កម្លាំង ប្រព្រឹត្តទៅអស់មួយយប់

មួយថ្ងៃនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុដែលឆាន់បន្ទាន់បិណ្ឌបាតនោះ បានបន្ទោបង់សេចក្ដីស្រេកឃ្លាន បាត់អស់កម្លាំងប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនោះឯងក៏មិនជាអ្វី ។ តែឯភិក្ខុទីមួយនោះឯង គួរជាទីបូជាដោយវិសេសផង ជាទីសរសើរបស់តថាគតផង ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថាការមិនឆាន់បន្ទាន់បិណ្ឌបាតនោះ អាចធ្វើឲ្យភិក្ខុនោះប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ដើម្បីសេចក្ដីសន្ដោស ដើម្បីមានចិត្តផូរផង់ ដើម្បីជាមនុស្សដែលគេចិញ្ចឹមងាយ ដើម្បីប្រារព្ធនូវព្យាយាមអស់កាលដ៏យូរអង្វែងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ! ព្រោះហេតុនោះ ក្នុងធម្មវិន័យនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។

ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះចប់ហើយ ក៏ស្ដេចក្រោកចាកអាសនៈទ្រង់ពុទ្ធដំណើរទៅកាន់វិហារ ។

កាលព្រះអង្គទ្រង់ព្រះពុទ្ធដំណើរទៅមិនយូរប៉ុន្មាន ព្រះសារីបុត្រដ៏មានអាយុក៏ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះហើយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ! ព្រះសាស្ដាទ្រង់មានសេចក្ដីស្ងប់ស្ងាត់ហើយ ពួកសាវ័កក្នុងសាសនានេះមិនហាត់ធ្វើនូវវិវេក មិនលះបង់នូវពួកធម៌ដែលព្រះសាស្ដាទ្រង់ត្រាស់ឲ្យលះបង់ បែរទៅជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់សាសនាធូរៗ នាំអាទិឲ្យប្រព្រឹត្តទន្ទាប ជាអ្នកដាក់ធុរៈក្នុងវិវេក

គឺមិនបំពេញកិច្ចក្នុងព្រះនិព្វាន ។ ម្នាលអាវុសោ ទាំងឡាយ ! បណ្ដាភិក្ខុទាំងនោះ ភិក្ខុជាថេរៈក្ដី ជាមជ្ឈិមក្ដី ជានវកៈក្ដី ទ័ងមានគេតិះដៀលដោយហេតុ ៣ យ៉ាង គឺ :

១ – ព្រះសាស្ដាទ្រង់មានសេចក្ដីស្ងប់ស្ងាត់ហើយ តែមានពួកសាវកមិនហាត់ដើរទូវវិវេក ។

២ – ពួកសាវកមិនលះបង់នូវធម៌ ដែលព្រះសាស្ដាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។

៣ – ពួកសាវកជាអ្នកប្រព្រឹត្តលោភច្រើន ជាអ្នកកាន់ (សាសនា) ធូរៗ នាំអាទិឲ្យប្រព្រឹត្តទន្ទាប ជាអ្នកដាក់ធុរៈក្នុងវិវេក ។

ម្នាលអាវុសោ ទាំងឡាយ ! ព្រះសាស្ដាទ្រង់មានសេចក្ដីស្ងប់ស្ងាត់ហើយ ពួកសាវកក៏សិក្សាតាមនូវវិវេកផង លះបង់នូវពួកធម៌ដែលព្រះសាស្ដាទ្រង់សំដែងប្រាប់ឲ្យលះបង់ផង មិនជាអ្នកប្រព្រឹត្តលោភច្រើនផង មិនកាន់ ( សាសនា ) ធូរៗ ផង មិនដាក់ធុរៈក្នុងការប្រព្រឹត្តទន្ទាបផង ជាប្រធានក្នុងវិវេកធម៌គឺព្រះនិព្វានផង ។ ម្នាលអាវុសោ ទាំងឡាយ ! បណ្ដាភិក្ខុទាំងនោះ ភិក្ខុជាថេរៈក្ដី ជាមជ្ឈិមក្ដី ជានវកៈក្ដី រមែងមានអ្នកផងសរសើរដោយហេតុ ៣ យ៉ាង គឺ

១ – ព្រះសាស្ដាទ្រង់មានសេចក្ដីស្ងប់ស្ងាត់ហើយ ទាំងពួកសាវកក៏សិក្សាតាមនូវវិវេក ។

៤ – ពួកសាវ័កជាអ្នកលះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។

៣ – ពួកសាវ័កមិនប្រព្រឹត្តលោភច្រើន មិនកាន់ (សាសនា) ធូរៗផង មិនដាក់ធុរៈក្នុងការប្រព្រឹត្តទន្លាបផង ជាប្រធានក្នុងវិវេកធម៌គឺព្រះនិព្វានផង ។

ម្នាលអាវុសោទាំងឡាយ ! ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ រមែងមានពួកសាវ័កជាអ្នកសិក្សាតាមនូវវិវេកដោយហេតុទាំង ៣ យ៉ាងប៉ុណ្ណេះឯង ។

ម្នាលអាវុសោទាំងឡាយ! មជ្ឈិមាបដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល ប្រព្រឹត្តទៅដើម្បីលះបង់នូវបាបធម៌ទាំងឡាយ មានលោភៈជាដើម ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ គឺឃើញនូវសច្ចៈទាំង ៤ ផងជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ គឺដឹងនូវសច្ចៈទាំង ៤ ផង ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ (ឯមជ្ឈិមាបដិទានោះ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត) ។

ព្រះសារីបុត្រដ៏មានអាយុ បានសំដែងសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអរពេញចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ។

ចប់

ការបណ្ដុះជំស្រួយ

## ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

## ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

ជាតិខ្មែរ ជាជាតិឯករាជ្យ មានព្រះមហាក្សត្រជាដំណសន្តតិវង្ស មកតាមលំដាប់ ដោយត្រឹមត្រូវតាមច្បាប់ទំលាប់នឹងប្រពៃណីនៃស្រុកទេស ៗ ព្រះមហាក្សត្រនោះព្រះអង្គជាអ្នកទ្រទ្រង់ទុកនៅព្រះរាជអំណាចក្នុងការញ៉ាំងករណីយកិច្ចរបស់ជាតិ ឲ្យដំណើរទៅកាន់សេចក្ដីសុខ សេចក្ដីចំរើនតាមរដ្ឋធម្មនុញ្ញ ព្រះអង្គជាប្រមុខនៃប្រជាជនខ្មែរ ទ្រង់គ្រប់គ្រងប្រទេសជាតិឲ្យតាំងនៅជារដ្ឋឯករាជ្យ មានឥស្សរភាពពេញលេញតរៀងទៅ ទ្រង់ជាអគ្គសាសនូបត្ថម្ភក៍ គឺព្រះអង្គត្ពោះព្រះកក្ត្រទំនុកបំរុងរក្សាព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងបិតថេរស្ថាពរ ដែលចាត់ថាជាប្រយោជន៍ដ៏ធំក្រៃលែងដល់ប្រទេសជាតិនឹងខ្លួនយើងជាពលរដ្ឋ មិនតែប៉ុណ្ណោះទ្រង់បានតាំងចេញទ្រង់ព្រះផ្នួស[១] ដើម្បីឲ្យបានជ្រាបច្បាស់

---

១ ព្រះមហាក្សត្រខ្មែរពីអតីតដែលចេញទ្រង់ព្រះផ្នួសក្នុងពុទ្ធសាសនានោះ មានច្រើនអង្គ តែបើពោលចំពោះព្រះមហាក្សត្រខ្មែរក្នុងបច្ចុប្បន្ននេះវិញ ក៏គឺព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ដែលចេញទ្រង់ព្រះផ្នួសកាលពីថ្ងៃទី ៣១ កក្កដា ដល់ថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៤៧ ។

នូវកិច្ចការពារផ្លូវព្រះពុទ្ធសាសនាផង ទ្រង់ជាអ្នកឃុំគ្រងពួកយើងឲ្យបានផុតភ័យអន្តរាយនៃជីវិត, រាងកាយនិងទ្រព្យសម្បត្តិ ឲ្យបានទទួលសេចក្តីសប្បាយរីករាយត្រជាក់ត្រជុំតៗ គ្នាមកដល់គ្រានេះ ។

ហេតុដូច្នេះ កាលបើយើងស្រឡាញ់ភក្ដីចំពោះជាតិហើយក៏ត្រូវតែស្រឡាញ់ភក្ដីចំពោះព្រះមហាក្សត្រ ដែលជាប្រមុខរបស់ជាតិផង ប្រៀបដូចជាយើងស្រឡាញ់គ្រួសារ ត្រូវស្រឡាញ់ភក្ដីចំពោះប្រធាននៃគ្រួសារ និងអ្នកដែលស្រឡាញ់ពួកគណៈ ត្រូវស្រឡាញ់ភក្ដីចំពោះប្រធាននៃពួកគណៈផងដូច្នោះ ។ អត្ថនៃសេចក្តីស្រឡាញ់ភក្ដីចំពោះព្រះមហាក្សត្រនោះ គឺ :

ក)- រាប់អានព្រះអង្គថាជាព្រះប្រិយមហាក្សត្ររបស់ខ្លួន ដោយចិត្តដ៏បរិសុទ្ធ ដូចជាបុត្រធីតាដ៏ល្អដែលស្រឡាញ់រាប់អានមាតាបិតារបស់ខ្លួន ថាជាមាតាបិតាយ៉ាងពិតប្រាកដដូច្នោះ ។

ខ)- ធ្វើសក្ការបូជា គោរពកោតក្រែង ចំពោះព្រះអង្គដោយកាយ វាចាចិត្ត មិនប្រព្រឹត្តល្មើសចំពោះព្រះអង្គដោយប្រការណាមួយ ដូចជាបុត្រធីតាដ៏ល្អដែលគោរពកោតក្រែងស្រឡាញ់ចំពោះមាតាបិតារបស់ខ្លួនជានិច្ច មិនប្រព្រឹត្តល្មើសដោយកាយ វាចា ចិត្ត ឬ គិតលុបលាងគុណមើលងាយយ៉ាងណាមួយដូច្នោះ ។

គ)- ជួយការពារនិងកំចាត់ភ័យវិបត្តិ មិនឲ្យមកប៉ះពាល់ព្រះពារលើព្រះអង្គបាន និងមិនធ្វើការណាមួយដែលជាហេតុឲ្យមានអន្តរាយចំពោះ

ព្រះអង្គ ឬជាហេតុមិនឲ្យព្រះអង្គបានសុខសំរាន្តក្នុងព្រះរាជហឫទ័យ ធ្វើតែការណាដែលចំរើនដល់ព្រះអង្គ នឹងដែលនាំឲ្យព្រះអង្គបានរីករាយព្រះរាជហឫទ័យ ដូចជាបុត្រធីតាដ៏ល្អ ដែលតាំងចិត្តប្រតិបត្តិបំរើមាតាបិតារបស់ខ្លួន ឲ្យនៅជាសុខសម្រាន្តដូច្នោះ ។

ជាតិខ្មែរអ្នកជាទាំងឡាយ សូមចាំទុកកុំភ្លេចថា "អង្គព្រះប្រិយ-មហាក្សត្រ តាំងនៅក្នុងឋានៈជាទីគោរពសក្ការបូជា អ្នកណាមួយនឹងល្មើសមិនបាន" ។ តែត្រូវកុំពោលត្រឹមសំដីឡើយ ត្រូវប្រតិបត្តិតាមអង្គនៃសេចក្តីស្រឡាញ់ភក្តីចំពោះព្រះមហាក្សត្រ ដូចពោលមកហើយដោយកតញ្ញូកតវេទី សុចរិតស្មោះត្រង់ គោរព សក្ការបូជា ចំពោះព្រះអង្គដោយចិត្តបរិសុទ្ធកុំខាន ។

៤.— ស្រឡាញ់ភក្តីចំពោះរដ្ឋធម្មនុញ្ញ.— រដ្ឋធម្មនុញ្ញ គឺច្បាប់ទំលាប់ដ៏ខ្ពស់បំផុតរបស់ប្រទេស ជាកំពូលនៃនីតិបញ្ញត្តិ គឺបញ្ញត្តិរបស់ច្បាប់ដែលមានអំណាចខ្ពស់បំផុតក្នុងផែនដី នឹងជាវិធីដំណើរការទៅសម្រាប់កំណត់នូវគ្រឿងនៃការគ្រប់គ្រងប្រទេស ឲ្យមានគោលចារិកម៉ាំមួនដែលគ្មាននរណាមួយ អាចនឹងធ្វើការគ្រប់គ្រងទៅតាមគាប់ចិត្តបានទាំងជាច្បាប់មានរបៀបការគ្រប់គ្រងប្រទេស ក្នុងន័យទំនុកបំរុងឲ្យកើតសុខរំងាប់ទុក្ខរបស់ប្រជាជននៃជាតិ ប្រគល់ឲ្យនូវសិទ្ធិក្នុងការគ្រប់គ្រងផ្ទះសម្បែងស្រុកទេស ដល់បណ្តាពស្ត្រី ផ្សារភ្ជាប់នូវព្រះមហាក្សត្រនឹង

ប្រជារាស្ត្រឲ្យរួមដៃគ្នា ចាត់ការគ្រប់គ្រងប្រទេសដោយសាមគ្គីធម៌ ទទួលធានាក្នុងការឃុំគ្រងសិទ្ធិរបស់ប្រជារាស្ត្រនៃជាតិ ទុកជាគោលចារឹក ចងភ្ជាប់នឹងការពាររក្សាប្រទេសជាតិ សាសនា ព្រះមហាក្សត្រ ឲ្យបិតថេរស្ថាពរជាយូរអង្វែងតរៀងទៅ ។

រដ្ឋធម្មនុញ្ញនេះ ក្រៅអំពីការប្រើជាច្បាប់ទំលាប់ដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រទេសហើយ គង់តែនៅជាសញ្ញាប្រជាគមរបស់ប្រជារាស្ត្រនៃជាតិទៀត ព្រោះអាចបង្កឲ្យកើតសាមគ្គីធម៌ ជាច្បាប់មានការចងភ្ជាប់ប្រជាជាតិ ឲ្យមានការជិតដិតស្និទ្ធស្នាលគ្នាយ៉ាងមាំមួន លែងឲ្យមានការរើសរូសដែលធ្លាប់តែមានដល់គ្នានឹងគ្នារវាងពួកនឹងរវាងជាន់ទៀត ជាបង្គោលសម្រាប់រក្សាសន្តិភាពខាងក្នុងបានទូទៅ ទាំងជារបងរនាំងដែកការពារប្រទេសឲ្យឈរជំហរនៅរឹងប៉ឹងយ៉ាងក្រៃលែង អាចធ្វើឲ្យប្រទេសជាតិកើតជាដុំជាដែនស្តុកស្តម្ភមាំមួនមានសន្តិសុខ នឹងឲ្យចំរើនរុងរឿងថ្កុំថ្កើងឡើងទាន់អារ្យប្រទេសធំៗ បានផង ។

ហេតុដូច្នេះ រដ្ឋធម្មនុញ្ញទើបជាអង្គការអំណោយសេចក្តីសុខ នឹងជាគោលទីពឹងដ៏ក្សេមក្សាន្តរបស់ប្រជាជាតិ បើមិនមានរដ្ឋធម្មនុញ្ញជាគ្រឿងរក្សាការគ្រប់គ្រងជីវិតរបស់ប្រជាជាតិឲ្យតាំងនៅជាសុខទេ ប្រជាជនក៏ខ្វះខាតវត្ថុឃុំគ្រងអស់១ចំណែក ដែលអាចនាំឲ្យមានសភាពតាំងនៅក្នុងការឃុំគ្រង នូវជីវិតមិនប្លែកអំពីសត្វតិរច្ឆាន ដូចពោលមកហើយខាង

ដើមនោះឡើយ ។ កាលបើរដ្ឋធម្មនុញ្ញ មានគុណភាពដ៏ខ្លាំងក្លាយ៉ាងនេះហើយ ពួកប្រជាជាតិខ្មែរ គួរតែស្រឡាញ់កក្ដីដកល់ទុកកងទ្ទខ្ពស់ទីងថ្មរក្សាទុកនូវរដ្ឋធម្មនុញ្ញនោះដោយសេចក្ដីពេញចិត្ត ដកបដល់កល្បាវសាន ឲ្យដូចជាជាតិ, សាសនា, ព្រះមហាក្សត្រដូច្នោះ គឺត្រូវប្រតិបត្តិតាមអង្គនៃសេចក្ដីស្រឡាញ់កក្ដី បំពោះរដ្ឋធម្មនុញ្ញដូចតទៅនេះ:-

ក )- គោរពស្រឡាញ់របៀបការគ្រប់គ្រងប្រទេសរបស់ខ្លួនតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។

ខ )- មិននិយមត្រែកអក្កងការគ្រប់គ្រងប្រទេសរបស់ខ្លួនដោយវិធីដទៃឬដែលខុសចាករដ្ឋធម្មនុញ្ញ ។

គ )- រក្សាការពារ និងទំនុកបំរុងផងដើមការគ្រប់គ្រងប្រទេសរបស់ខ្លួន ឲ្យដំណើរទៅត្រូវត្រង់គ្រប់គ្រាន់ តាមវិធីនៃរដ្ឋធម្មនុញ្ញ ។

ឃ )- ទំការពារឃាត់យ៉ាងកំហាត់បង់នូវអំពើដែលជាគ្រឿងបំផ្លិចបំផ្លាញរដ្ឋធម្មនុញ្ញ និងការគ្រប់គ្រងតាមរបៀបដទៃ ឬដែលខុសចាករដ្ឋធម្មនុញ្ញរបស់ខ្លួន ។

ង )- ប្រតិបត្តិខ្លួនឲ្យត្រូវ តាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ដើម្បីឲ្យសម្រេចប្រយោជន៍ដល់ខ្លួននិងជាតិ ។

លោក-អ្នកកម្ពុជាទាំងឡាយ! នេះហើយជាអង្គនៃសេចក្ដីស្រឡាញ់កក្ដីបំពោះរដ្ឋធម្មនុញ្ញ ។ សូមនឹកជានិច្ចថា "រដ្ឋធម្មនុញ្ញ មិនមែនប្រតិបត្តិ

តាមលោក-អ្នកទេ លោក-អ្នកទេតើ ដែលត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ហើយរដ្ឋធម្មនុញ្ញនោះ បើលោកអ្នកប្រតិបត្តិតាមហើយ អាចពិតភក្តីរក្សា លោក-អ្នកឲ្យមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា ឲ្យបានទទួលប្រយោជន៍ ពេញលេញ ឲ្យមានសិទ្ធិ ឥស្សរភាព សេរីភាពដោយខ្លួនទៅគ្រប់គ្នា ។

វត្ថុដែលឃុំគ្រងយើងទាំង ៤ គឺ ជាតិ, សាសនា, ព្រះមហាក្សត្រ និង រដ្ឋធម្មនុញ្ញនេះ រមែងជាបង្គោលនៃសេចក្តីសុខ និងជាទីពឹងដ៏ក្សេមក្សាន្ត របស់ប្រជាជាតិកម្ពុជា ។ ជាតិ តែងឃុំគ្រងយើងឲ្យជាខ្មែរអ្នកជា មាន ឥស្សរភាព ។ សាសនា តែងឃុំគ្រងយើង ឲ្យជាមនុស្សបរិសុទ្ធ ។ ព្រះមហាក្សត្រ តែងឃុំគ្រងយើង ឲ្យបានសេចក្តីត្រជាក់ត្រជុំជា កិត្តិយស ។ រដ្ឋធម្មនុញ្ញ តែងគ្រប់គ្រងយើងឲ្យមានសិទ្ធិសេរីភាព. សមភាពនិងភាតរភាពដោយពេញលេញ ។

ដូច្នេះ ពួកយើងគ្រប់គ្នា ទើបគួរស្រឡាញ់ភក្តីចំពោះជាតិ, ចំពោះ សាសនា, ចំពោះព្រះមហាក្សត្រ និងចំពោះរដ្ឋធម្មនុញ្ញ ដោយទឹកចិត្ត ដ៏បរិសុទ្ធស្អាតផូរផង់ ។ ពួកយើង ចូរយល់ឲ្យច្បាស់ថា ជីវិតដែល ប្រកបដោយសេចក្តីស្រឡាញ់ភក្តីចំពោះវត្ថុឃុំគ្រងទាំង ៤ នេះ ជាជីវិត នៃកិត្តិយសដ៏ខ្ពង់ខ្ពស់ ។ ឯជីវិតដែលប្រកបដោយការវៀចវេរទុយិស លុបគុណគេ មើលងាយគេ ជាជីវិតនៃមរណភាពមុនមរណកាល ។

កើតស្លាប់តែ១គ្រា គ្មាននរណាស្លាប់ ២ ដង
ដូច្នេះត្រូវកុំកន្តង ត្រូវទឹកជាតិជាងជីវិត ។

ព្រោះបើជាតិសាបសូន្យ ខ្មែរទាំងក្បួនត្រូវភ័យកិត
បានទុក្ខទញ់គំនិត កែខែគិតក៏លែងបាន ។
កាលជាតិសាបសូន្យហើយ នរណាឡើយនឹងសុខសាន្ត
មានតែមនុស្សតិរច្ឆាន ទើបក្សេមក្សាន្តក្រោមជើងគេ ។
សាសនានៃព្រះពុទ្ធ គ្មានតំរុទ្ធខណាទេ
អាចនាំអស់យើងគេ ឆ្ពោះទៅកាន់សន្តិសុខ ។
ដូច្នេះយើងទាំងឡាយ ត្រូវខ្វល់ខ្វាយកុំសំកុក
ប្រតិបត្តិឲ្យពេញមុខ ដើម្បីសុខប្រទេសជាតិ ។
ព្រះប្រិយមហាក្សត្រ សោយសម្បត្តិជាទាយាទ
ព្រះអង្គតែងខ្មីឃ្មាត ស្វែងរកសុខមកឲ្យរាស្ត្រ ។
ដូច្នេះខ្មែរទាំងឡាយ ត្រូវខ្វល់ខ្វាយកុំទសទាស
នាំគ្នាប្រឹងពេញពាស មកគោរពស្ដាប់ព្រះអង្គ ។
រដ្ឋធម្មនុញ្ញ ជាគ្រឿងផ្ចួញជនមិនត្រង់
ជាច្បាប់កែតម្រង់ នូវការខុសឲ្យត្រូវបាន ។
ជាគោលនៃបញ្ញត្តិ ទាំងវិបត្តិគ្រប់ទំហាន
ដឹកនាំជនគ្រប់ប្រាណ ឲ្យក្សេមក្សាន្តមានសេរី ។
ដូច្នេះខ្មែរទាំងគត់ ត្រូវគោរពដោយឃ្មាតខ្មី
លើកដាក់លើសិរសី កុំគប្បីបណ្ដោយឡើយ ។

(មានត)

# រឿងសាមកុក

## គណ្ឌទី ១៦

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការផ្លាស់បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

អង់ហោក៏និយាយនឹងចូឆូថា ស្រូវនៅក្នុងស្រុកយើងនោះកាន់តែតិចណាស់ទៅហើយ យូរទៅប្រហែលជាហានទាំងពួងនឹងខ្វះខាត ។ ចូឆូឆ្លើយថា បើដូច្នោះត្រូវតែអ្នកគិតគូរបែកស្រូវឲ្យទាហាននោះ បន្ថយបំនួនឲ្យតិចជាងមុនឲ្យល្មមនឹងបង្ការទុក ត្រាតែការយើងនោះសម្រេច ។ អង់ហោជំរាបថាដែលលោកនឹងធ្វើដូច្នោះ ខ្ញុំបាទឃើញថាទាហានទាំងពួងនឹងមានសេចក្ដីតូចចិត្ត ព្រោះបរិភោគមិនឆ្អែតគ្មានកំឡាំងធ្វើការ គង់នឹងប្រែចិត្តមិនគិតខំប្រឹងធ្វើការរឿងរេគ្គណ៍សង្គ្រាម ។ ចូឆូតបថា យើងនឹងរិះគិតមិនឲ្យទាហានទាំងពួងតូចចិត្តបាន គឺត្រូវធ្វើថាំងឲ្យតូចរាល់ស្រូវ

វែកទាហាន ។ អង់ហៅក៏ធ្វើតាមពាក្យប្ដូរថា ។ ទាហានទាំងពួងទទួលយកស្រូវទៅធ្វើអាហារបរិភោគ មិនបានគ្រប់គ្រាន់ពេញកំឡាំងក៏តូចចិត្តណាស់ នាំគ្នានិទាប្ដូរថា ចំណែកខាងការងារបេះតែប្រើឲ្យធ្វើ ចំណែកខាងអាហារឲ្យស្រូវស៊ីមិនឆ្អែតពេញលេញ បើមិនមានកំឡាំងហើយកាលណាឡើយនឹងធ្វើសឹកសង្គ្រាមដូចម្ដេចបាន ។

លុះដល់មជ្ឈិមយាម ប្ដូរក៏ប្រើបំរើដែលទំនុកទុកចិត្ត ឲ្យទៅលបចាំស្ដាប់សេចក្ដី ដែលទាហានទាំងពួងនិយាយតូចចិត្តនោះ ក៏បានឮសំឡេងនិយាយគ្នានិទាប្ដូរផ្សេងៗ ប្ដូរក៏តាំងរិះគិតយកចិត្តសេនាទាហានឲ្យមានសេចក្ដីខំប្រឹងធ្វើការលើកគ្នាចូលប្ដូនយកស្រុកនោះ ក៏ឲ្យហៅខុនអង់ហៅមកនិយាយថា យើងនឹងសុំរបស់ជាសំឡាញ់នៃអ្នកតែម្យ៉ាងនឹងបានយកចិត្តសេនាទាហាន អ្នកនឹងឲ្យយើងបានឬទេ? ។ អង់ហៅឆ្លើយថា ខ្ញុំបាទគ្មានរបស់អ្វីនឹងឲ្យមហាឧបកដទេ ។ ប្ដូរឆ្លើយឡើបថា យើងចង់ខ្ចីក្បាលអ្នក អង់ហៅក៏តក់ស្លុតរន្ធត់កង់ចិត្តឆ្លើយថា ខ្ញុំបាទគ្មានទោសខុសពីអ្វីសោះ ហេតុម្ដេចមហាឧបកដចង់កាត់ក្បាលខ្ញុំបាទដូច្នោះ ។ ប្ដូរឆ្លើយថា "ខុនអ្នកគ្មានទោសខុសពីអ្វីទេ តែថាយើងសុំកាត់ក្បាលជាឧបាយឲ្យសេនាទាហានជឿចូលចិត្តគិតខំធ្វើការ សូម្បីកិរិយាបុត្ររបស់អ្នកនឹងស្ងួតគ្រប់គ្រួសារដែលនៅខាងក្រោយ យើងនឹងទទួលបីបាច់ថែរក្សាចិញ្ចឹមព្យាបាល មិនឲ្យមានសេចក្ដីតោកយ៉ាកលំបាកតទៅមុខឡើយ"

និយាយហើយ អង់ហោវមិនទាន់ទឹងថាដូចម្តេចផង ចូឆូក៏ប្រើទាហានឲ្យចាប់ខ្លួនអង់ហោវនាំទៅកាត់ក្បាលក្នុងវេលានោះ ហើយដោតក្បាលផ្កាល ស្រែកអាប្រកាសថា អង់ហោវធ្វើជានាយឃ្លាំងស្រូវ បំហូវតែបំបាត់មហាឧបាយកលបល្លួចធ្វើថាំងតូចវាល់ស្រូវចែក ឲ្យទាហានបានស៊ីមិនគ្រប់គ្រាន់ ៗ

ខណៈនោះ បណ្ដាទាហានទាំងពួងក៏បានដឹងឃើញគ្រប់គ្នា ក៏អស់សេចក្ដីសង្ស័យ ៗ ចូឆូក៏ឲ្យប្រកាសឃោសនា ឲ្យបណ្ដាទាហានទាំងពួងចូលមកបើកស្រូវឲ្យសម្រេចក្នុងរវាង ៣ ថ្ងៃ ហើយចូឆូក៏ឲ្យកំផាប់ពាក្យទឹងទាហានទាំងពួងថា "យើងទឹងលើកទ័ពចូលវាយទំលាយយកស្រុកក្នុងវេលានេះ បើនរណាមិនមានចិត្តតាំងទឹងប្រឹងធ្វើការទេ ឲ្យចេញមុខមក យើងទឹងកាត់ក្បាលចេញ" ហើយក៏ដេញទាហានឲ្យដឹកដីទំលុះកំពែងស្រុកនោះ ៗ ទាហានក្នុងកំពែងក៏ឡើងលើសែនបាញ់ធ្នូប្រមេះចេញមក ហើយទំលាក់ដុំថ្មចុះមកទៀតបីដូចគ្រាប់ភ្លៀង ៗ ទាហានចូឆូ ២ នាក់ដែលចូលទៅដឹកគូទំលាយកំពែងនោះ ក៏ថយមកវិញ ព្រោះខ្លាចព្រួញនិងដុំថ្ម ៗ ចូឆូឃើញក៏យកគ្របីកាត់ក្បាលទាហានទាំង ២ នាក់នោះស្លាប់ ហើយបោះទម្លាក់ក្នុងគូនោះ ៗ ទាហានទាំងឡាយឃើញដូច្នោះក៏មិនអាចទឹងរាថយមកវិញ ៗ ចូឆូក៏បង្ខំឲ្យទាហានដឹកកកាយទំលាយកំពែងធ្លាយចូលទៅក្នុងស្រុកបាន ៗ ទាហានចូឆូក៏ចាក់កាប់សម្លាប់ក្នុងទ័ពក្នុង

ស្រុកវិនាសស្លាប់ជាច្រើន ហើយព្រឹត្តគ្នាចាប់បានខ្លួន ឡោហង, តាន់គី, ងាក់ងីវ, លៀងកង ទាំង ៤ នាក់ ។ ប៉ូឆ្វួសួរកអ៊ូនស៊ុតថា រត់ទៅតាំងទ័ពនៅទីណា? ។ ឈ្មោះ៤នាក់ឆ្លើយថា អ៊ូនស៊ុតរត់ទៅស្រុកហ្វួយ-ណាំ ។ ប៉ូឆ្វួក៏ឲ្យយកខ្លួនទាំង ៤ នោះទៅសម្លាប់ផ្ដាលកណ្ដាលផ្សារ ឲ្យបណ្ដាអ្នកស្រុកក្រឡេកឃើញទាំងអស់គ្នា ។ ឯរបស់ទ្រព្យដែលមាននៅក្នុងស្រុកនោះ ប៉ូឆ្វួក៏ឲ្យដឹកញូនយកមកចំណាយចែកចាយឲ្យសេនាទាហានតាមសមគួរ ហើយឲ្យដុតផ្ទះសំបែងក្នុងក្រុងស្រុកនោះអស់ឥតសល់ ។

ប៉ូឆ្វួក៏ប្រឹក្សានឹងសេនាទាហានទាំងពួងថា យើងនឹងលើកទ័ពទៅតាមអ៊ូនស៊ុត តើអ្នកទាំងពួងនឹងយល់ឃើញដូចម្ដេច? ។ ស៊ុនហុកឆ្លើយថា វេលានេះស្បៀងអាហាររបស់យើងក៏រៀវស្ដួចណាស់ហើយ បើនឹងលើកទ័ពទៅតាមអ៊ូនស៊ុតនោះ ខ្ញុំបាទយល់ឃើញថា ទាហានទាំងពួងនឹងបានសេចក្ដីទៀយព្រួយលំបាក សុំឲ្យលោកលើកត្រឡប់ចូលទៅក្រុងហ៊ូតោវិញស្រួលជាង ព្រោះនឹងបានបំរុងសេនាទាហានឲ្យមានបរិបូណ៌សិន បើដល់រដូវស្រូវទុំក្នុងស្រែវេលាណា សឹមត្រឡប់មកធ្វើការគង់នឹងបានដោយស្រួល ។ ប៉ូឆ្វួបានស្ដាប់ព្រោះខាងមិនទាន់គិតជាយ៉ាងណា ទទួលៈទាហានជូនសំបុត្រមកដល់ប៉ូឆ្វួថា គៀវស៊ុំជាក្មួយគៀវបេតប់គិតគ្នានឹងឡោះពៀវដែលនៅស្រុកកេងជីវ លើកទ័ពទៅវាយស្រុកសៀងយ៉ុង

នឹងស្រុកកាំងឡេង បានតតាំងច្បាំងគ្នានឹងពោហាង ជាច្រើនគ្រា ហើយពោហាងធន់ថ្វីដៃតៀវស៊ីវមិនបានសុំឲ្យមហាឧបរាជលើកទ័ពទៅជួយ ។ ចូចូឃើញសេចក្ដីសំបុត្រដូច្នោះ ក៏និយាយនឹងស៊ុនសិកថា អ្នកចូរលើកទ័ពទូកទៅកំពង់ស្កាត់ពីក្រោយផ្លូវស្រុកកេងជីវទុកឲ្យមាំ ដើម្បីនឹងឲ្យឡៅ-ពៀវអន្ទូះសាពវែកកុំឲ្យធ្វើការតទៅបាន កាលណាយើងប្រឹងប្រែងរៀបចំការខាងណោះស្រេច នឹងលើកទ័ពទៅស្រុកសៀងយ៉ុងនឹងស្រុកកាំងឡេង វាយទំលាយគយពីមុខ ។

ស៊ុនសិកទទួលពាក្យចូចូហើយក៏លើកទ័ពចេញទៅ លុះស៊ុនសិកទៅដល់ហើយ ចូចូក៏ឲ្យហៅលីប៉ោនឹងឡៅពីមកនិយាយថា អ្នកទាំង ២ កុំបីមានចិត្តគិតអាឃាដព្យាបាទគ្នាតទៅមុខឡើយ ត្រូវតែជួយគ្នាគិតទំនុកបំរុងផែនដីដើម្បីឲ្យព្រះចៅហៀនតេទ្រង់បានសេចក្ដីសុខ យើងនឹងសុំឲ្យឡៅពីត្រឡប់ទៅនៅស្រុកសៀវផាយវិញ ។ លីប៉ោទទួលពាក្យចូចូហើយក៏លាលើកទ័ពត្រឡប់ទៅស្រុកឈីជីវ ។ ចូចូក៏និយាយនឹងឡៅពីថា អ្នកដឹងកល់យើងឬទេ? យើងឲ្យអ្នកទៅនៅស្រុកសៀវផាយវេលានេះ យើងនឹងបញ្ជោតឲ្យខ្លាធ្លាក់អណ្ដូង បើអ្នកទៅហើយចូរត្រិះរិះគិតគូរគ្នានឹងតាន់គុយតាន់តេង ធ្វើការឲ្យសំរេចបានជាដាច់ ។ ឡៅពីក៏លាចូចូទៅតាំងនៅស្រុកសៀវផាយ ។ ចូចូក៏លើកទ័ពត្រឡប់ទៅស្រុកហ៊ូតោ ហើយប្រមូលពលយោធាលើកទៅច្បាំងនឹងតៀវស៊ីវ ។ ទទួល

ទាហានចូលទៅជំរាបប្ចូថា ទួនអ៊ុយទឹងង៉ស៊ុបសម្លាប់លីឈុយគុយគីស្លាប់ហើយ ត្រូវយកក្បាលទាំង ២ នោះទឹងស៊ុំគ្រប់បក្សពួកមកជូនលោក ៗ ប្ចូមានសេចក្តីត្រេកអរណាស់ចេញមកទទួលទួនអ៊ុយទឹងង៉ស៊ុប ហើយឲ្យទាហាននាំយកស៊ុំគ្រប់បក្សពួកលីឈុយគុយគីទៅកាប់យកក្បាលដោតផ្លាលក្រៅទ្វារស្រុក ហើយនាំយកសេចក្តីនោះទៅក្រាបបង្គំទូលព្រះចៅហៀនតេ ៗ ទ្រង់ជ្រាបគ្រប់ប្រការ ទ្រង់មានព្រះរាជហឫទ័យសោមនស្សត្រេកអរថា "ផែនដីយើងវេលានេះនឹងបានសេចក្តីសុខអស់ចម្រូងចម្រះហើយ" ទើបមានព្រះជម្រាស់ឲ្យហៅខុនទួនអ៊ុយទឹងង៉ស៊ុបចូលទៅក្រាបបង្គំគាល់ក្នុងទីព្រះរាជរោងរម្យ ហើយទ្រង់ប្រោសព្រះរាជទានលៀងអាហារ ឲ្យទួនអ៊ុយទឹងង៉ស៊ុបបរិភោគជាមួយនឹងនាហ្មឺនខ្ញុំរាជការទាំងពួង រួចទ្រង់ព្រះរាជទានតាំងទួនអ៊ុយជាចងទៅចៀងគុន, តាំងង៉ស៊ុបជាទៀន-លោធៀងគុន គឺនាយទាហានកំចាត់ចោរ ហើយមានព្រះជម្រាស់ឲ្យទួនអ៊ុយទឹងង៉ស៊ុប នាំស៊ុំគ្រប់បក្សពួកទៅឈរស្រុកតៀវអាន ៗ ទួនអ៊ុយទឹងង៉ស៊ុបក៏ក្រាបថ្វាយបង្គំលាទៅឈរវែខត្រូវតាមព្រះតម្រាស់ ៗ ប្ចូក៏ក្រាបបង្គំទូលព្រះចៅហៀនតេថា តៀវស៊ីវគប់គិតគ្នានឹងឡាវពៀវលើកទ័ពទៅវាយស្រុកសៀវយ៉ុងនឹងស្រុកកាំងឡេង ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជទានថ្វាយបង្គំលា លើកទ័ពទៅកំចាត់តៀវស៊ីវក្នុងសម័យនេះ ឯរាជការគ្រប់ចំពូកក្នុងក្រុង ទូលព្រះបង្គំជាខ្ញុំចាត់ឲ្យស៊ុនហុតនៅត្រួតត្រា

វក្យា" ហើយក៏ថយទៅរៀបចាត់ចែងសេនាទាហានលើកចេញពីទីក្រុង ទៅ ។ ព្រះចៅហៀនគេស្តេចជូនដំណើរចូឡដល់ក្លោងទ្វារ ។ ព្រះចៅហៀនគេសោយរាជសម្បត្តិគង់ក្រុងហ្វូគោបាន ៣ ព្រះវស្សា ។

កាលចូឡលើកទ័ពទៅនោះ ជារដូវស្រូវកោដសាលីកំពុងទុំស្រុះ បណ្តាមនុស្សម្នាមហាជនដែលនៅក្បែរខាងផ្លូវ ដឹងឃើញថាកងទ័ពចូឡលើកទៅដល់ទីណា ក៏នាំគ្នាភ័យខ្លាចរត់ចោលស្រែចម្ការអស់ ។ ចូឡឃើញដូច្នោះក៏ហាមប្រាមនាយទ័ពនាយកងទាំងពួងថា "បើនរណាទៅបៀតបៀនបណ្តារាស្ត្រអ្នកស្រុក ឬដើរជាន់ស្រូវកោដសាលីសូម្បីតែ ១ គុម្ពក្តី យើងនឹងកាត់ក្បាលនាយទ័ពនាយកងនោះទុកជាបំរាម" រួចក៏ឲ្យប្រកាសឃោសនាប្រាប់ប្រាមបណ្តារាស្ត្រអ្នកស្រុក ដែលភ័យរត់ទៅនោះឲ្យវិលមកនៅគង់ភូមិឋានដូចដើមវិញ ។ រាស្ត្រអ្នកស្រុកវិលមកឃើញរបស់ទ្រព្យមិនមានខូចបាត់អន្តរាយ ហើយឮថាចូឡហាមប្រាមពលទាហានដូច្នោះ ក៏មានសេចក្តីត្រេកអរសរសើរគ្រប់គ្នាថា មហាឧបរាជមានសេចក្តីប្រណីអាណិតរាស្ត្រណាស់ នឹងរកអ្នកឯណាស្មើគ្មាន ។

ឯនាយទ័ពនាយកងទាំងពួង កាលលើកទ័ពទៅដល់ពាក់កណ្តាលផ្លូវ បើត្រូវលើផ្លូវស្រែនៅទីណា ក៏លោតចុះពីលើសេះ ដៃដឹកសេះវៃកគុម្ពស្រូវកោដសាលីដើរទៅព្រោះខ្លាចអាជ្ញាចូឡ សូម្បីតែខ្លួនចូឡឯងនោះសោត ក៏ជិះសេះប្រែទាហានវៃកគុម្ពស្រូវពីខាងមុខដរាប លុះសេះនោះ

ដើរទៅ មានសត្វ ១ នៅក្នុងស្រែភ្លើលហើរឡើង សេះនោះក៏ភ្ញាក់ស្ទុះប្រឡោតចូលទៅក្នុងស្រែ ជាន់ជញ្ជាំងគុម្ពស្រូវកោជសាលីបាក់ល្អិតជាច្រើនគុម្ព ចូឆូឃើញដូច្នោះ ក៏ធ្វើឧបាយដើម្បីនឹងឲ្យទាហានទាំងពួងស្រឡាញ់រាប់អាននឹងកោតខ្លាច ព្រោះឃើញថាយុត្តិធម៌តឹមត្រូវណាស់ ក៏តាំងឲ្យហៅនាយទ័ពនាយកងទាំងពួងមកប្រាប់ថា ឥឡូវខ្លួនយើងបានធ្វើខុសនឹងអាជ្ញា ហើយឲ្យអ្នកទាំងពួងកាត់សេចក្ដីទោសយើងចុះ ។

ដូផៅទីប្រឹក្សាក៏ជំរាបសួរចូឆូថា មហាឧបរាជធ្វើខុសពីអ្វី? ។ ចូឆូក៏ពណ៌នារឿងរ៉ាវប្រាប់ពីសេះភ្លើលជាន់គុម្ពស្រូវនោះ ឲ្យដូផៅស្ដាប់ថា "ពីដើមយើងដាក់អាជ្ញាហាមប្រាមពួកពលទាហានទាំងអស់ ថាបើធ្វើខូចបាក់បែកគុម្ពស្រូវរបស់រាស្ត្រត្រូវមានទោស ឥឡូវត្រូវលើខ្លួនយើងធ្វើខុសខ្លួនឯង បើនឹងស្ងៀមបំបាត់សេចក្ដីនោះចេញ បណ្ដាមនុស្សទាំងពួងក៏នឹងតិះដៀលដំនៀលថា ខ្លួនយើងមិនបានតាំងនៅក្នុងផ្លូវសត្យយុត្តិធម៌" ថាហើយហូតក្រប៉ីដែលសៀតពីក្រោយនោះចេញ ធ្វើទំនងជានឹងអារកខ្លួនឯងសម្លាប់ ។

គុយកៃក័យស្ទុតស្ទុះរត់ទៅដណ្ដើមក្រប៉ីពីដៃចូឆូបានហើយឃាត់ថា ដែលមហាឧបរាជធ្វើដូច្នេះក៏គួរណាស់ហើយ តែថាខ្លួនខ្ញុំបាទនឹងនាយទ័ពនាយកងនៅទាហានទាំងពួងនៅជាសុខបាន ក៏ព្រោះតែព្រះតេជព្រះគុណមហាឧបរាជឃុំគ្រងរក្សា វេលានេះបើមហាឧបរាជនឹងសម្លាប់ខ្លួន

ឯងចេញ យើងខ្ញុំទាំងឡាយក៏គ្មានទីពឹងពំនាក់សោះ, ព្រះគុណអើយ តាំងពីថ្ងៃនេះទៅក៏នៅមានតែទុក្ខព្រួយលំបាកពន់ពេកណាស់ ៗ ចូចូស្តាប់ច្បាស់ក៏ធ្វើជាដកដង្ហើមធំហើយនិយាយថា "អ្នកជាដូច្នេះត្រូវហើយ តែអ្នកនឹងសុំឲ្យជាប់តាមពាក្យនោះមិនបានទេ ត្រូវតែយើងធ្វើឲ្យមានបែបផែនទុក" ថាហើយក៏យកក្រប៊ីកាត់សក់ពីលើក្បាលរបស់ខ្លួនហុចឲ្យទៅទាហានកាន់យកទៅស្រែកអាក្រោសគ្រប់តំបន់តាមផ្លូវថា មហាឧបរាជធ្វើខុសនឹងអាជ្ញាហើយ ក៏មិនបានសោកស្តាយដល់ជីវិតគិតនឹងសម្លាប់ខ្លួនចេញ តែបណ្ដានាយទ័ពនាយកងនាំគ្នាសុំអង្វរឲ្យលើកទោស បានជាមហាឧបរាជកាត់សក់នេះជំនួសក្បាល ឲ្យអ្នកទាំងឡាយមើលឲ្យឃើញជាបែបផែនតទៅចុះ ៗ បណ្ដាសេនាទាហាននឹងអាណាប្រជានុរាស្ត្រទាំងពួង ក៏នាំគ្នាសរសើររាប់អាននឹងកោតខ្លាចអំណាចចូចូលើសជាងពីដើម ៗ ចូចូក៏បង្គិពលយោធាលីលាស្រុតរូតទៅច្បាំងនឹងគៀវស៊ីវ ៗ

ឯគៀវស៊ីវនោះលុះដឹងថាចូចូលើកទ័ពមក ក៏ចាត់សំបុត្រទៅដល់ឡេវពៀវឲ្យលើកទ័ពមកខ្ទប់វាយពីក្រោយ ខ្លួនគៀវស៊ីវនឹងលុយឈើ, គៀវសៀនក៏លើកទាហានទៅតាំងនៅក្រាំបន្ទាយចាំទទួលច្បាំងនឹងចូចូ ៗ ទទួលចូចូលើកទ័ពមកដល់ ៗ គៀវស៊ីវឃើញចូចូស្រែកជេរថា អាចោរជាងចេះសំដីពិរោះឲ្យមនុស្សវង្វេងជឿ អញមិនដឹងថាអាឯងចេះក្បត់កុហកអាក្រក់លើសសត្វតិរច្ឆាន ៗ ចូចូបានឮដូច្នោះក៏ខឹងណាស់ ដេញទៅជូ

ឲ្យបំផាយុះសេះចូលទៅគយុទ្ធនឹងគៀវស៊ុីវ។ ក៏ប្រើគៀវសៀនឲ្យចេញមកតស៊ូនឹងខេះជូបាន ៣ ក្នុង ។ ទៅជូយកទ្ធនចាក់គៀវសៀនធ្លាក់ពីលើសេះស្លាប់ ។ គៀវស៊ុីវឃើញដូច្នោះ ក៏គិតថានឹងតស៊ូនឹងជូមិនបាន ទើបបរសេះវេះនាំទាហានចូលទៅក្នុងស្រុកសៀវយ៉ុង ហើយឲ្យបិទទ្វារស្រុកទុកជុំវិញមាំមួន ហើយចាត់ទាហានឲ្យឡើងយាមល្បាតលើសែនកំពែង ។

ជូក៏លើកទាហានឡោមព័ទ្ធជុំវិញពីក្រៅ មើលទៅឃើញជ្រលជ្រៅពន្ទឹក បើនឹងលុយកាត់ទឹកទៅក៏មិនបាន ទើបប្រើទាហានឲ្យដឹកជញ្ជូនឈើនឹងស្មៅមកចងទុកជាច្រើន ហើយសង់សែនល្បាតតាមច្រកទ្វារស្រុកទាំង ៤ ទិស ជូឡើងឡើងមើលគ្រប់សែនពេញ ៣ ថ្ងៃ ឃើញទាហានដែលល្បាតលើសែនកំពែងទិសខាងកើតស្ងប់ស្ងៀម ក៏ប្រើទាហានឲ្យដញ្ជូនកេប៊ីនឹងស្មៅ ទៅគរទុកខាងទ្វារបស្ចឹម ហើយប្រាប់ទាហានទាំងពួងថា យើងនឹងលើកវាយទំលាយល្បាតទិសនេះ ។

កាសៀងទីប្រឹក្សាឃើញដូច្នោះក៏ជំរាបគៀវស៊ុីវថា ដែលជូឲ្យរៀបចាត់ការដូច្នេះ ខ្ញុំបាទយល់ថា ធ្វើជាកលឧបាយ ខ្ញុំបាទសូមធ្វើកលទល់ប្រាជ្ញាជូវិញឲ្យចាញ់យើងឲ្យបាន ។ គៀវស៊ុីវក៏សួរទៅកាសៀងថា អ្នកនឹងគិតធ្វើកលទល់ប្រាជ្ញាជូនោះ តើនឹងគិតធ្វើដូចម្ដេច? ។ កាសៀងជំរាបថា ខ្ញុំបាទឃើញជូឡើងលបមើលលើសែន ៣ វេលាហើយ ជូឃើញទាហានខាងយើងទិសបូព៌ានោះស្ងៀមស្ងប់ បានជាជូ

ឲ្យជញ្ជូនយកឈើនឹងស្មៅទៅគរទុកខាងទិសបស្ចិម ដើម្បីនឹងឲ្យយើងប្រុងប្រយ័ត្នខាងទិសបស្ចិម ឯគំនិតចូឆូប្រែត្រឡប់ទៅទំលាយខាងទិសបូព៌ាទេ គឺបំណងនឹងធ្វើក្នុងពេលយប់នេះជាប្រាកដ ខ្ញុំបាទនឹងបង្គាប់ឲ្យពួកអ្នកស្រុកស្លៀកពាក់តែងខ្លួនបន្លំទៅជាទាហាន ឡើងទៅរក្សាគយខាងទិសបស្ចិមបែបប្រុងប្រយ័ត្នឲ្យមាំមួន តែពួកទាហានទាំងអស់របស់យើងៗត្រូវប្រមូលមកបង្កប់ចាំខាងទិសបូព៌ាវិញ បើចូឆូលើកមកធ្វើការវេលាណា យើងឲ្យអុចផាវជាសញ្ញា ឯទាហានដែលបង្កប់ឲ្យចេញមកខ្ទប់ទាំងសងខាង គង់តែចូឆូនឹងបរាជ័យរបស់យើងជាប្រាកដ ៗ តៀវស៊ីវយល់ឃើញត្រូវ ក៏បង្គាប់ឲ្យធ្វើតាមពាក្យកាសៀងថា នោះជាស្រេច ។

ឯទាហានដែលគយឃ្លាំយាមល្បាត ក៏នាំយកហេតុទៅជំរាបចូឆូថា ឥឡូវតៀវស៊ីវ ប្រមូលសេនាទាហានទៅបំរុងការប្រយ័ត្នខាងទិសបស្ចិមច្រើនណាស់ ឯខាងទិសបូព៌ាក៏មានទាហានបន្តិចបន្តួចស្តួចស្តើងទេ ។ ចូឆូបានស្តាប់ដូច្នោះ ក៏សោមនស្សត្រេកអរស្មានក្នុងចិត្តថា នឹងសមប្រកបតាមគំនិតគិតទុក ទើបបង្គាប់ទាហានទាំងពួងឲ្យប្រុងប្រៀបរៀបខ្លួនកាន់គ្រឿងសស្ត្រាវុធទុកឲ្យព្រមគ្នា ។ លុះពេលយាម ៣ ប្រាយ ចូឆូក៏បរពលឲ្យចុះហែលទឹកក្នុងគូធ្វងទៅខាងទិសបូព៌ាដល់ទ្វារកំពែង ស្តាប់សំឡេងក៏មិនមានមនុស្សនឹងតវ៉ា ទាហានទាំងអស់គ្នា ក៏ពារទំលាយចូលតាមទ្វារទៅក្នុងស្រុកបាន ។

(មានត)

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

លោក រ៉ាយ-ប៊ុក ក្រមការ

ប្រែពីបារាំងមកជាខ្មែរ

(តមក)

## រឿងទីដប់ប្រាំពីរ

អារក្សក្រាបទូលមហារាជថា: “បពិត្រមហារាជ! មានព្រាហ្មណ៍ម្នាក់នាមទេវសម៌(Dévas harma) មានគេហដ្ឋាននៅនគរឧជ្ជេន (Ujjain) ។ ព្រះមហាក្សត្រទ្រង់ព្រះនាមមហាសេន (Mahà sain) សោយរាជ្យនៅនគរនោះ ។ ទ្រង់មានព្រះរាជបុត្រមួយអង្គព្រះនាម គុណេករ (Tunèkar) ។ ព្រះរាជបុត្រអង្គនេះជាអ្នកលេងល្បែងស៊ីសងហួសប្រមាណ ចាញ់អស់ធនធានដែលព្រះបិតាទ្រង់ព្រះរាជទាន ទាល់តែក្រុមព្រះរាជវង្សានុវង្សបណ្តេញទ្រង់ចេញពីព្រះនគរ ។

ព្រះអង្គម្ចាស់ទ្រង់ស្តេចចេញពីព្រះនគរ គ្មានភោគទ្រព្យបន្តិចបន្តួចជាប់ទៅជាមួយសោះឡើយ ។ ដល់ទ្រង់ស្តេចទៅអស់ពីរបីថ្ងៃ, បានទៅដល់នគរមួយ ។ នៅនគរនោះ ទ្រង់បានទតឃើញព្រះយោគីមួយរូបអង្គុយមានផ្សែងចេញពីប្រមុះ ។ ទ្រង់បានសំដែងគារវភាពចំពោះព្រះយោគីនោះរួចក៏គង់នៅក្នុងទីដ៏សមគួរ ។ ព្រះយោគីក៏ក្រាបទូលសួរទ្រង់

ថា ទ្រង់មានព្រះបំណងចង់សោយព្រះក្រយាឬទេ ! ។ ទ្រង់តបវិញថា: «ម្ដេចក៏ខ្ញុំមិនចង់បរិភោគ ឲ្យតែលោកឲ្យមកខ្ញុំចុះ អាហារអ្វីក៏ដោយ» ។

ព្រះយោគីក៏បានយកលោកក្បាលខ្មោចមនុស្សមួយ មកដាក់អាហារ ហើយក៏យកមកថ្វាយទ្រង់ ។ ដល់ព្រះយោគីឃើញថាព្រះអង្គម្ចាស់ មិនសោយនូវក្រយាហារទាំងនោះ ព្រះយោគីនោះក៏សូត្ររូបមន្តមួយបទ ស្រាប់តែមានយក្ខិនីមួយមកដល់ ។

យក្ខិនីនោះ លើកដៃអញ្ជលីថ្វាយបង្គំព្រះយោគីហើយពោលថា: «ឱព្រះអង្គ ! ខ្ញុំម្ចាស់នឹងធ្វើតាមបង្គាប់ព្រះអង្គទាំងអស់» ។ ព្រះយោគីក៏បានបង្គាប់ទៅយក្ខិនី ឲ្យយកអាហារដែលព្រាហ្មណ៍ (ព្រះអង្គម្ចាស់) នេះ ត្រូវការទៅជូនព្រាហ្មណ៍ ។ យក្ខិនីក៏បានសាងប្រាសាទមួយល្អស្អាត ហើយក៏បាននាំយកវត្ថុទាំងប៉ុន្មាន ដែលជាទីតម្រេក យកទៅតម្កល់ក្នុងប្រាសាទនោះ ។ រួចយក្ខិនីនាំយកព្រាហ្មណ៍នោះ ទៅអង្គុយលើកៅអីមួយ ហើយក៏យកម្ហូបអាហារថែមទាំងខាទនីយាហារជាច្រើនយ៉ាង ។ កាលណាព្រាហ្មណ៍បានបរិភោគនូវភោជនាហារ ដែលឆ្ងាញ់ពិសារួចហើយ, យក្ខិនីបានយកហិបម្លូមួយមកដាក់ចំពីមុខ ហើយក៏បានលាបប្រស់ព្រំសព្វសព៌ាង្គកាយនូវរមៀត, ទឹកចន្ទន៍ លាយនឹងទឹកផ្កាកុលាបគ្រអូបឈ្ងុយឈ្ងប់ ហើយយកសំលៀកបំពាក់មានសភាពស្ដើងសាច់ហ្មត់ ប្រោះទឹកអប់, យកបុប្ផាកម្រងមកពាក់ក ហើយក៏នាំព្រាហ្មណ៍នោះមកលើគ្រែក្នុងពេលនោះ ។ បន្តិចទៀត, ជូនជាយប់, នាងយក្ខិនីក៏មកអង្គុយ

ជិតព្រាហ្មណ៍, ហើយនិទ្រាជាមួយព្រាហ្មណ៍របួតមួយកគ្រែ, សប្បាយត្រេកត្រអាលក្នុងកិលេសកាមនឹងវត្ថុកាម ។ លុះដល់បុព្វណ្ហសម័យ, នាងយក្ខិនីនោះក៏វិលត្រឡប់ទៅទីកន្លែងវិញ ។ ព្រាហ្មណ៍ក៏ទៅប្រាប់ព្រះយោគីនោះថា: "លោកគ្រូ! នាងយក្ខិនីទៅបាត់ហើយ តើលោកគ្រូឲ្យខ្ញុំធ្វើយ៉ាងណា" ។ ព្រះយោគីពោលថា: "នាងយក្ខិនីនេះមកក្នុងទីនេះបានដោយអានុភាពវិជ្ជា ហើយនាងអាចស្ថិតនៅបាន ចំពោះបុគ្គលណាដែលអាចសង្កត់សង្កិននូវចិត្ត កុំឲ្យលុះក្នុងកាមតណ្ហា" ។

ព្រាហ្មណ៍នោះក៏តបទៅព្រះយោគីវិញថា: "សូមលោកគ្រូមេត្តាប្រគល់នូវវិជ្ជានោះមកខ្ញុំៗ នឹងយកទៅប្រើការតាមត្រូវការ" ។

ព្រះយោគីក៏បានឲ្យទៅព្រាហ្មណ៍នូវរូបមន្តមួយបទ រួចបង្គាប់ថា: "ចូរអញ្ជើញទៅអង្គុយនៅក្នុងទឹករាល់យប់ ក្នុងពេលពាក់កណ្ដាលអធ្រាត្រ ឲ្យអស់រយៈវេលាសែសិបថ្ងៃ ដោយមានចិន្តាថានឹងសិក្សារៀនសូត្រឲ្យចាំស្ទាត់នូវរូបមន្តនោះ" ។

ព្រាហ្មណ៍នោះ ក៏ធ្វើតាមបង្គាប់ព្រះយោគីសព្វគ្រប់ប្រការ, ហើយពិតមែនតែមានទុគ្គហនិមិត្តគួរឲ្យតក់ស្លុតភ័យខ្លាច. ព្រាហ្មណ៍ក៏មិនមានខ្លាចអ្វីសោះឡើយ ។ កាលណាពេលវេលាដែលកំណត់ផុតហើយ ព្រាហ្មណ៍ក៏វិលត្រឡប់មកប្រាប់ព្រះយោគីថា: "លោកគ្រូ! ខ្ញុំបានធ្វើតាមបង្គាប់លោកគ្រូហើយ" ។ ព្រះយោគីតបថា: "ចូរបំពេញកិច្ចដែល តាម

កំតែពេលដូចមុន, អង្គុយនៅក្នុងភ្លើង" ។ តែព្រះអង្គម្ចាស់គុណេករ ទ្រង់បានសូមអនុញ្ញាតព្រះយោគីទៅសួរគ្រួសារបានម្ដង, ដោយសន្យានឹងព្រះយោគី ថាបំពេញកិច្ចរួច នឹងវិលត្រឡប់មកប្រព្រឹត្តប្រតិបត្តិតាមលោកគ្រូមិនហ៊ាននាន ។

ព្រះអង្គម្ចាស់គុណេករ លុះបានអនុញ្ញាតហើយ ក៏ស្ដេចវិលត្រឡប់មកកាន់នគរវិញ ។ ដល់ទ្រង់ស្ដេចទតយល់នូវព្រះមាតាបិតានឹងព្រះរាជវង្សានុវង្ស ទ្រង់ក៏លោតទៅឱបព្រះសូវង, ហើយទ្រង់ព្រះកន្សែងជាមួយនឹងព្រះរាជវង្សានុវង្ស ។ ព្រះបិតាមានបន្ទូលថា: "ឱគុណេករ! តើកូនឯងទៅឯណា ក្នុងរយៈវេលាយូរម៉្លេះ? ហេតុម្ដេចក៏ឯងភ្លេចផ្ទះសម្បែងដូចនេះ? ។ ឱកូនអើយ! មានគម្ពីរពោលថា: អ្នកណាបោះបង់ចោលភរិយា ដែលមានចិត្តស្មោះត្រង់នឹងខ្លួន ស្ថិតនៅឆ្ងាយពីនាង មិនស្រឡាញ់នាង, តែនាងមានចិត្តភក្ដីនឹងស្វាមីពន់ពេក, អ្នកនោះ គេទុកជាអ្នកនិរទេស ។ មានគម្ពីរខ្លះពណ៌នាថា: គុណសម្បត្តិអ្វីមិនស្មើនឹងគុណសម្បត្តិគ្រួសារសោះឡើយ, ជាអ្វីក្នុងពិភពលោក មិនអាចធ្វើខ្លួនឲ្យសប្បាយ ទឹកមុខស្រស់ស្រាយបាន ក្រៅពីស្ត្រីដែលនៅក្នុងគេហដ្ឋាន, ជាអ្នកណាដែលប្រមាថមើលងាយមាតាបិតា, គេទុកជាមនុស្សថោកទាប ហើយព្រះព្រហ្មមានព្រះរាជឱង្ការថា: "អ្នកទាំងអស់នោះគ្មានអ្នកណាស្រោចស្រង់ឲ្យផុតពីទុក្ខបាន" ។

ព្រះអង្គម្ចាស់គុណករទ្រង់ក្រាបទូលព្រះបរមកជបិតាវិញថា: "រូបកាយនេះមានឈាមនឹងសាច់ជាសមាសភាព គឺជាអណ្ដែងដង្វ, បើតាមធម្មជាតិរបស់វា វាមានកំសួលផ្សាយជាក្លិនស្អុយ បើយើងមិនបានថែទាំរូបកាយនោះថ្ងៃណាមួយ ។ អ្នកណាមិនស្រឡាញ់រូបកាយនេះ អ្នកនោះជាមនុស្សល្ងង់, ហើយអ្នកណាដែលគ្មានចិត្តប្រកាន់ខ្ជាប់ស្អិតទៅនឹងរូបកាយអ្នកនោះគេទុកជាបណ្ឌិត ។ កើតនឹងស្លាប់នេះជាបទបញ្ញត្តិច្បាប់នៃរូបកាយទាំងនេះ ។ តើយើងនឹងអាចទុកចិត្តលើរូបកាយនេះបានឬទេ? បើទុកជាយើងចង់ធ្វើឲ្យរូបកាយមានសភាពបរិសុទ្ធស្អាតយ៉ាងណា, ក៏រូបកាយនោះមិនបេះបរិសុទ្ធទៅបាន ។ ដូចបើគេយកសម្រាមទៅដាក់ ថូនោះមិនអាចស្អាតបានទេ ។ គេលាងហើយលាងទៀតនូវដុំធ្យូង ក៏ដុំធ្យូងនោះមិនអាចប្រែជាពណ៌សបានឡើយ ។ តើធ្វើម្ដេច រូបកាយនេះដែលមានវត្ថុមិនស្អាត, ស្មោកគ្រោក, ចេញចូលជានិរន្ដរ៍, ធ្វើឲ្យទៅជាស្អាតបាន?" ។

ព្រះអង្គម្ចាស់គុណករទ្រង់មានបន្ទូលដូចនោះហើយទ្រង់បន្ថែមតទៅទៀតថា: "តើមាតាមានអ្វី? តើបិតា, ភរិយា, បងប្រុសមានអ្វី? គឺជាបទបញ្ញត្តិច្បាប់នៃពិភពលោក, កើតហើយស្លាប់ ។ ចុះអ្នកណាធ្វើពលិកម្មហើយនឹងសក្ការបូជាដោយយល់ថាព្រះអគ្គីជាព្រះអាទិទេព ហើយអ្នកណាដែលគ្មានវិចារណញ្ញាណយល់ថាអាក្រក់អ្នកតាជាព្រះអាទិទេពរបស់

ខ្លួន ៗ ពួកយោគីគិតថា ព្រះហរិស្ថិតនៅក្នុងខ្លួន ៗ ខ្ញុំមិនបានបំពេញករណីយកិច្ចខាងគ្រួសារ, តែខ្ញុំរស់នៅប្រព្រឹត្តប្រតិបត្តិតាមវិន័យយោគី" ៗ

ដល់ទ្រង់មានព្រះបន្ទូលដូចនោះហើយ, ទ្រង់ក៏ចេញពីព្រះបរមរាជវាំង, វិលត្រឡប់ទៅកាន់អាស្រមព្រះយោគីវិញ ហើយទ្រង់គង់នៅលើក្អឹង សូត្របូមន្តគាថា, តែយក្ខិនីនោះមិនវិលត្រឡប់មកវិញសោះឡើយ ៗ រួចទ្រង់បានស្តេចទៅរកព្រះយោគី ៗ ទូលសួរទ្រង់ថា: "វិទ្យាសាស្ត្រ (ប្រហែលជាយក្ខិនី) មិនមកឬ?" ៗ ទ្រង់មានបន្ទូលតបថា "មិនឃើញមកទេ, លោកគ្រូ!" ៗ

អាវក្សបានពណ៌នានូវរឿងនេះចប់សព្វគ្រប់, ទើបក្រាបបង្គំទូលសួរមហារាជថា: "បពិត្រព្រះចមកព! ហេតុដូចម្តេចបានជាវិជ្ជាមិនចូលមកស្ថិតនៅក្នុងចិត្តនៃទ្រង់គុណករ?" ៗ

ព្រះមហារាជទ្រង់មានព្រះបន្ទូលតបទៅអាវក្សវិញថា "បានជាវិទ្យាសាស្ត្រ (មិនដឹងជាយក្ខិនី ឬ យក្ខិនីនេះជាបដិមារូបនៃវិជ្ជាសាស្ត្រ ឬ វិជ្ជា, ឬក៏ការត្រាស់ដឹងឃើញច្បាស់នូវធម៌?) មិនមក ព្រោះថាព្រះអង្គម្ចាស់នេះ ទ្រង់មានព្រះទ័យឃ្លេងឃ្លោង ហើយគេពោលថា: "អ្នកណាដែលមានចិត្តនឹងនួន, រូបមន្ត្រនោះអាចឲ្យផលដ៏វិសេសវិសាល" មានគេពោលថា: "កិត្តិនាមមិនអាចមានបានចំពោះអ្នកណាដែលជាអសប្បុរស, អ្នកណាដែលគ្មានសច្ចធម៌, អ្នកនោះ ជាអហិរិកបុគ្គល

(impudent) ។ អ្នកណាដែលប្រព្រឹត្តទុច្ចរិត អ្នកនោះមិនអាចមានភោគទ្រព្យឡើយ ហើយអ្នកណាមិនដែលធ្វើសមាធិចិត្ត អ្នកនោះមិនអាចឃើញព្រះអាទិទេព” ។

អារក្សវេតាល (Baitâl) ក្រាបបង្គំទូលសួរមហារាជតទៅទៀតថា: “ព្រះអង្គម្ចាស់ ទ្រង់មានព្រះបំណងចង់បាននូវវិជ្ជាវិសេសវិសាលនោះ ទ្រង់ធ្លាក់ក្នុងភ្លើង, តើត្រង់ណាដែលទ្រង់ប្រមាទ?” ។

មហារាជត្រាស់តបទៅអារក្សវិញថា: “ព្រះអង្គម្ចាស់ទ្រង់មិនបាននៅសិក្សារៀនសូត្របមន្ត្រនោះ ទ្រង់ស្តេចទៅសួរព្រះរាជវង្សានុវង្សវិញ, បានជាព្រះយោគីខ្ញាល់ ហើយពោលថា: ម្តេចក៏បង្ហាត់បង្រៀនវិជ្ជាដល់សាវ័កដែលមានចិត្តកាយមាយដូចនេះ ព្រោះហេតុដូចនេះ បានជាទ្រង់មិនបាននូវវិជ្ជានោះ ហើយមានគេពោលថា: ជោគវាសនាត្រួតត្រាលើមនុស្សលោក ទោះមនុស្សនោះមានពលកាយយ៉ាងណាក៏ដោយ, ឬបំពេញកិច្ចការដោយប្រាជ្ញាយ៉ាងណា, មនុស្សនោះត្រូវទទួលផលតាមអំណាចរបស់ជោគវាសនាទាំងអស់” ។

អារក្សដែលបានឮមហារាជទ្រង់មានព្រះបន្ទូលចប់សព្វគ្រប់, ក៏វិលត្រឡប់ទៅកាន់រុក្ខជាតិដូចពីដើម, ហើយមហារាជទ្រង់បានទៅយកអារក្សនោះលីលើព្រះអង្សាហើយក៏នាំយកទៅ ។

ចប់ រឿងទី ១៧ មានរឿងទី ១៨ តទៅទៀត

# រឿងស្លាប់ព្រោះជាតិ

## មាន ៣ ឈុត

## លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

---

វិន្ទី

ទេ ខ្ញុំថាមិនជ្រុលទេអ្នក ! ខ្ញុំគិតយ៉ាងនេះគឺខ្ញុំគិតដល់អ្នកដែរ ។

តារា

ទេ បើអ្នកគិតដល់ខ្ញុំ អ្នកមិនអាចនឹងហ៊ានប្រព្រឹត្តបែបហ្នឹងទេ ។

វិន្ទី

ណ្ហើយ ! គំនិតស្មុគស្មាញច្រើន ខ្ញុំមិនចូលចិត្តទេ ! ខ្ញុំចង់ឲ្យការនេះបានសម្រេចយ៉ាងឆាប់, ឯណាអានោះទៅណាបាត់ហើយ, អ្នកឯងយកទៅលាក់ហើយឬ? ។

តារា

និយាយឲ្យស្រួលបួលអ្នក ! ប្រសាសន៍របស់អ្នកថ្ងៃមកនេះ មិនគួរឲ្យខ្ញុំផ្ទៀងត្រចៀកស្តាប់ទេ ! ហើយមិនគួរអ្នកហ៊ានពោលពាក្យយ៉ាងនេះចំពោះមុខខ្ញុំសោះ ខ្ញុំមិនត្រូវការទៅលាក់កូនរបស់អ្នកធ្វើអ្វី ។

វិន្ទី

បើអ្នកមិនលាក់ ម្តេចក៏កូនខ្ញុំមិនដែលឃើញទៅផ្ទះខ្ញុំសោះ តាំងតែពីប្រពន្ធវាស្លាប់ទៅ, ជាង ១ អាទិត្យហើយ វាមិនដែលឃើញទៅអើតផ្ទះខ្ញុំ ខ្ញុំឆ្ងល់ណាស់ ។

តារា

ត្រង់កូនអ្នកទៅកើតផ្ទះឬមិនទៅ ខ្ញុំឥតបានទៅដឹងរឿងហេតុនោះទេ កុំបាច់អ្នកឆ្ងល់ធ្វើអ្វី មិនដែលមាន គ្នាកំពុងតែព្រួយចិត្ត ដេកកើតទុក្ខរាល់ថ្ងៃហើយឲ្យគ្នាឧស្សាហ៍ដើរទៅមកទៀត, អ្នកមិនដឹងទេ តើកូនអ្នកសព្វថ្ងៃ កើតទុក្ខយ៉ាងណា ? ។

វទ្ធី

ព្រោះតែវាកើតទុក្ខហ្នឹងហើយ បានជាខ្ញុំរកប្រពន្ធឲ្យវាទៀតដើម្បីនឹងធ្វើកុំឲ្យវាកើតទុក្ខពេក ឲ្យវាលែងទុក្ខបន្តិច ។ នែអ្នក! វាកើតទុក្ខតែនៅមិនទាន់បានគ្នាទេ តែដល់វាបានគ្នាជាប្តីប្រពន្ធទៅ វាភ្លេចបាត់ទៅហើយ សេចក្តីទុក្ខសោករបស់វានោះ ។

តារា

ការត្រង់ហ្នឹង ខ្ញុំពុំអាចនឹងអធិប្បាយជំរាបអ្នកបានទេ ! ស្រេចតែលើគំនិតអ្នកបេះកែខែទៅចុះ ។

ភាគទី ២

## វទ្ធី-រាតា-តារា

តារា

មើលកូនប្រុសម្តាយ ! ម្តាយចង់សួរកូនឯង អំពីរឿងប្រពន្ធកូនឯងក្រោយនេះបន្តិច, តឡូវម៉ាក់ឯងយកអ្នកឯងទៅរៀបការក្នុងថ្ងៃ

ស្អែកនេះ ឯខេត្តស្វាយរៀង តើឯងនឹងថាយ៉ាងដូចម្ដេច? កិច្ចត្រង់ហ្នឹង ស្រេចតែឯងប៉ះលែលកទៅចុះ ម៉ាក់មិនរាំងរាំង មិនបង្ខិតបង្ខំឯងទេ ស្រេចតែតាមអំពើចិត្តឯងចុះ ។

ភាគា

អ្នកម្ដាយ! សូមអ្នកម្ដាយជ្រាបថា សេចក្ដីស្នេហារបស់ខ្ញុំ លែងផុះផាលកើតឡើងទៀតហើយ គឺលែងត្រូវការនឹងរូបស្ត្រីដែលយកមកធ្វើជាប្រពន្ធជាកូនទៀតទេ ។ ខ្ញុំស៊ូទ្រាំនៅពោះម៉ាយយ៉ាងដូច្នេះ ឲ្យទាល់តែអស់ជីវិត ។

តារា

ចុះបើម្ដាយរបស់ឯង បានជណ្ដើងកូនគេហួសទៅហើយ តើឯងនឹងអាចឲ្យម្ដាយឯងឈប់ឯណាបាន ។ នែកូនប្រុសម្ដាយ! ពាក្យចាស់លោកថា "ស្វាបង់ប្រាក់កុំឲ្យតែបង់សំដី" ឬថា "វនាបប្រាក់គ្រាន់នឹងដូសបាន បើសំដីហួស គ្មានអ្វីនឹងដូសបានទេ" ហេតុនេះកូន! ចូរឯងគិតឲ្យវែងឆ្ងាយ ។ អាណិតម្ដាយឯង ឬអាណិតកូនប្រសើរជាង? ទៅលើរូបទាំង ៣ នេះ ស្រេចតែលើឯងលែលកគិតមើលទៅ ។ ឯរូបម្ដាយមិនអីទេ, ហាក់ដូចជាជើងក្រោយទេ ។

ភាគា

អ្នកម្ដាយរបស់ខ្ញុំ ពិបាកណាស់ បើខ្ញុំគិតតែតាមសេចក្ដីអាណិតអាសូរដល់ទ្រូងរបស់គាត់នោះ គឺខ្ញុំត្រូវតែទទួលធ្វើតាមសំដីរបស់គាត់ ។

ប៉ុន្តែបើតាមចិត្តដែលក្តៅនឹងគាត់ធ្វើហួសយ៉ាងដូច្នេះ គឺខ្ញុំមិនយកទេ អាណិតកូនណាស់ កូននៅតូច កំពុងស្រឡាញ់កិច្ចការរៀនសូត្រ, តែខ្ញុំបានប្រពន្ធមួយទៀត ប្រហែលជាវាមិនសូវគិតនឹងកិច្ចការរៀនសូត្រប៉ុន្មានទេ រវល់តែប្រទូសរ៉ាយនឹងម្តាយចុងវាជាពុំខាន ។ ហើយបើខ្ញុំរស់នៅវាក្រាន់បើ ចុះបើខ្ញុំស្លាប់ទៅ ប្រហែលជាម្តាយចុង គេមិនត្រែកត្រអាលនឹងទំនុកបំរុងឲ្យរៀនសូត្រ បានពេញលេញដូចជាខ្ញុំរស់នៅទេ ។

អ្នកម្តាយសូមមេត្តាអត់ទោសទៅចុះ ខ្ញុំមិនព្រមទទួលយកទេ ។

វិជ្ជ

ចុះឯងមិនព្រមធ្វើម្តេចនឹងកើត បើអញដណ្តឹងកូនគេហួសទៅហើយ ។

ភាគា

អ្នកម្តាយអញ្ជើញទៅនិយាយជូនគេទៅវិញទៅ ! រូបមនុស្សវាមិនមែនដូរប្តូរដូចជាចំណីអាហារនោះទេ ។

វិជ្ជ

ទេ ! អញជាមនុស្សធ្លាប់តែគេអង្វរ អញមិនដែលទៅអង្វរអ្នកណាឲ្យបានម្តងទេ តាំងតែពីអញដឹងក្តីកាលណាមក គឺសុទ្ធតែគេ

និយាយអង្វរមករកអញ ដោយពាក្យទន់, តែគេអង្វរអញ អញមិនដែលទៅលើកដៃសំពះអ្នកណាឲ្យបានម្តងទេ ។

ភាគា

អ្នកម្តាយ! សេចក្តីគោរពរបស់មនុស្សប្រុសភាព មិនជាការពិបាកប៉ុន្មានទេ, មិនថោកអ្វីនឹងដៃ ថ្ងៃអ្វីនឹងមាត់ គេគ្រាន់តែឮសំដីរបស់យើងត្អូញត្អែរ គេគ្រាន់តែឃើញដៃយើងលើកឡើងនឹងសំពះ គេទន់ចិត្ត មានសេចក្តីអាណិតដល់យើងភ្លាម ។

វិទ្ធី

ទេ! បើដូច្នោះឯងទៅអង្វរខ្លួនឯងចុះ អញមិនទៅទេ អញខ្មាសមុខគេណាស់ ។

ភាគា

ឲ្យខ្ញុំទៅម្តេចនឹងបាន! ខ្ញុំមិនមែនជាអ្នកជំណាំងឯណា គឺរូបអ្នកម្តាយទេតើ ដែលជាអ្នកមេបានោះ ខ្ញុំទៅនិយាយនឹងគេមិនកើតទេ ។ មិនមែនអង្វរគេថាមិនយកទេ តែកន្លងរាង ១០ ឬ ២០ ឆ្នាំតទៅមុខទៀត ខ្ញុំព្រមទទួលយក ។

វិទ្ធី

បើយ៉ាងដូច្នេះ ឯងមិនចាំបាច់ថាអង្វរធ្វើអ្វីទេ! ឯងថាឯងមិនយកតែម្តងទៅ រស្រួលជាជាង ។ អញដឹងហើយ កិរិយារបស់ឯងនេះ

ឯងរកតែឧបស័គ្គណាដែលយកមកកាំងជំទាស់ការណ៍ហ្នឹង ឲ្យតែខាងការមិនកើត ៗ ឯងគ្រាន់តែហាមាត់ឡើងភ្លាម អញយល់ភ្លាម គឺដូចជាដាងគំនូរគ្រាន់តែរាសឡើង គេអាចស្គាល់រូបគំនូរបាន ៗ

ភគា

អ្នកម្តាយគិតមើល! ឲ្យខ្ញុំទទួលដូចម្តេច បើខ្ញុំនៅតែកើតទុក្ខណែនក្នុងដើមទ្រូង មិនទាន់បានល្ហែបន្តិចផង ៗ អ្នកម្តាយ! ខ្ញុំសូមជំរាបនូវពាក្យ ១ ឃ្លាខាងក្រោយនេះថា ជាតិនេះគឺខ្ញុំប្រាថ្នាតែមួយនឹងមួយ ខ្ញុំសូមសច្ចាថានឹងមិនឲ្យស្ត្រីឯណាមកប៉ះពាល់ដល់ខ្លួនខ្ញុំបានទៀតទេ ខ្ញុំសុខចិត្តនៅពោះម៉ាយ ពាក់កំណាត់ខ្មៅកាន់ទុក្ខនាងប្រពន្ធខ្ញុំ ឲ្យទាល់តែខ្ញុំអស់ជីវិត ៗ

រិទ្ធិ

ចុះអាភគា! អាឯងក៏ភគៈអ៊ូប្រៀនម៉្លេះអា៎! ទៅ ទៅ! អាឯងទៅដេកអោបផ្នូរប្រពន្ធអាឯងទៅ ៗ អ្នកតាភ! ត្រូវអ្នកកំចាត់អាហ្នឹងឲ្យវាចេញពីលើផ្ទះអ្នកទៅ រំលងឲ្យវានៅ ខ្ញុំស្អប់ណាស់, អាដែងកូនមិនស្តាប់បង្គាប់ ៗ ខ្ញុំចង់តែប្តឹងភជការខាងក្រុមនគរបាលឲ្យមកចាប់អាហ្នឹងដាក់រថយន្តឈ្លាបនេះតែម្តង ៗ

គាភ

ទ! អ្នកម្តាយចង់ទៅប្តឹង ឲ្យក្រុមនគរបាលមកចាប់ខ្ញុំទៅការ ៗ ទ! អ្នកម្តាយអើយ ខ្ញុំមិនដែលបានប្រទះនឹងច្បាប់ប្តុំមាត្រានៃរដ្ឋធម្មនុញ្ញ

ត្រង់ណាសំដែងអំពីរឿងអាពាហ៍ពិពាហ៍ដោយបង្ខំនេះទេ, ពជការលោកមិនមែនយល់ខុសដូចអ្នកម្ដាយមានប្រសាសន៍នេះឡើយ ។

### វឌ្ឍី

លែងនិយាយ ! នែអ្នកតាព ! អ្នកហើយជាកសិណសាក្សីរបស់ខ្ញុំ ! ខ្ញុំនឹងប្ដឹងដាក់ទោសអានេះ ឲ្យគេយកពទៅក្រសួងតុលាការតែម្ដង ! អាកូនរឹងរូស ! អាកូនមិនដោយដំបូនមាន ! អាកូនព្រហើនកោងកាច ! ។

(ចេញ)

### តារា

មើលសព្វៗទៅ ហាក់ដូចជាពិបាកនឹងនិយាយណាស់ ! ទំនងដូចជាខូចសតិបញ្ញាអស់ទៅហើយ បានជាចេះតែពោលពាក្យបែបយ៉ាងដូច្នេះ ។

### វាគា

ប្អូនម៉ាក់សង្កេតមើលចុះ ! កិរិយារបស់អ្នកម្ដាយខ្ញុំ ! គាត់ជាមនុស្សប្រកាន់ច្រើនណាស់ ! ជាមនុស្សមានះ ចចេស ខ្លួនខុសប្រកាន់ថាជាត្រូវ និយាយឥតបើគិត អាងតែខ្លួនអ្នកមានសម្បត្តិ ។

### តារា

កូនឯងត្រូវប្រយ័ត្នពាក្យសំដីរបស់ឯងឲ្យមែនទែន កុំពោលពាក្យទ្រគោះបោះបោកឲ្យគាត់ បើទុកជាខឹងយ៉ាងណាក៏ដោយ ចេះតែនិយាយឲ្យស្រួលទៅ, ធ្វើម្ដេចបាស់យ៉ាងដូច្នេះហើយ រញ៉ាំរញ៉ូវច្រើនណាស់ ។

ឯងមិនព្រមទេ! គាត់ចូលមកដល់ផ្ទះភ្លាម ស្រាប់តែថាអញលាក់ឯង អញចង់បានឯង គាត់មកដាក់ផ្លូវផ្កាឲ្យអញ សុទ្ធតែអញមេម៉ាយស្រពោន សុទ្ធតែអញអ៊ីៗ ឯណាតែផ្កាស ។ (ភគាចេញ)

## ឆាកទី ៣

# ភគី-ភគា-វណ្ណនារី

ភគី

លោកប៉ាមានរឿងហេតុអ្វី ក៏ចេះតែព្រួយតែខ្ញុំផងៗ អ៊ូសមៀមម៉េះ? ។

ភគា

កូន! លោកយាយរបស់ឯងគាត់ខឹងណាស់ ព្រោះប៉ាមិនព្រមទៅរៀបការកូនថៃស្អែកនេះ ឥឡូវគាត់ទៅប្ដឹងក្រុមនគរបាលបាត់ទៅហើយ ឲ្យគេមកចាប់ប៉ាដាក់រថយន្ដយកទៅការកូនថៃស្អែកនេះ ។

ភគី

លោកយាយ! ឱលោកយាយអើយ! លោកយាយមិនខ្វាសគេទេ កូនអំពើរបៀបហ្នឹង, គ្រាន់តែកិច្ចអាពាហ៍ពិពាហ៍របស់កូនឯងចាំបាច់ទៅប្ដឹងដល់ពដការឲ្យនាំអំពល់ទុក្ខ ដោយរឿងរំកាច់កោចយ៉ាងដូច្នេះ ។ លោកប៉ាកុំទៅឲ្យសោះណាលោកប៉ា! បើអំណាពហ៊ានមកចាប់ ទុកឲ្យខ្ញុំភ័យជំនួសលោកប៉ា ខ្ញុំកុំព្រួញតែស្អប់ប៉ូលិសអូចៗ យ៉ាងនេះផង ។

នៃវណ្ណនារីអូន! លោកយាយយកប៉ាទៅការកូនថៃស្អែកនេះហើយ ។

(ភគាចូល)

វណ្ណនារី

ប្រាកដហើយប្អូនឯង! ចុះលោកយាយម្ដេចក៏ប្រញាប់អ្វីសម្បើមម្ល៉េះ, ម៉ាក់ខ្ញុំស្លាប់ទៅមិនទាន់បាន ១ អាទិត្យផង ម្ដេចក៏បន្ទុំរៀបការយ៉ាងដូច្នេះៗ

ភារី

នែ, លោកយាយទៅប្ដឹងប៉ូលិសហើយ! ឲ្យគេមកចាប់ប៉ាយើងយកទៅរៀបការ ពីព្រោះប៉ាលោកប្រកែកណាស់ ៗ

វណ្ណនារី

បងកុំភ័យ! មិនអីទេការប្ដឹងបណ្ដឹង បងទុកឲ្យខ្ញុំយំឲ្យទាល់តែគេធ្វើការមិនកើត បងកុំភ័យឲ្យសោះ ខ្ញុំស្រែកយំឲ្យផ្អើលគេឯង នៅឡើទាល់តែគេលែងប៉ាទើបខ្ញុំសុខចិត្ត ៗ

ភារី

ប្អូនយំចុះ! ទុកឲ្យបងវាយ! បងវាយទាំងអស់ អាណាចូលផ្ទះយើងទាំងប៉ុន្មាន ៗ

វណ្ណនារី

បងឯងវាយលោកយាយដែរឬ?

ភារី

វាយទាំងអស់ឲ្យតែប៉ះមុខ! យាយហ្នឹងវិតតែវាយច្រើនជាងគេផង ព្រោះតែយាយហ្នឹងគឺដែលជាអ្នកនាំខូច យាយហ្នឹងហើយជាមេប៉ះប៉ោរៗ

(មានត)

# រឿងប៉ូល នឹងវីរស៊ីនី

លោក ផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

---

ដំបន់ដែលឯងនៅអាចឲ្យឯងធ្វើនូវអំពើល្អ បានដោយងាយអាចឲ្យឯងតាំងខ្លួនជាមនុស្សចិត្តល្អ និយាយពិត ស្មោះត្រង់ មានតម្រិះបេះអត់ទ្រាំ ស្គាល់ប្រមាណ ចិត្តបរិសុទ្ធ ចិត្តទូលាយ បេះអាណិត មានគុណធម៌ក្នុងខ្លួន គ្មានអកុសលធម៌ណាមួយមកធ្វើឲ្យរញ៉េមចិត្តដ៏ផូរផងរបស់ឯងដែលកំពុងរីក ៗ ទេព្តាឲ្យឯងមានឯកច្ឆានចិត្តគ្មានពេគា មានចិត្តស្មោះចំពោះការងារ មានមិត្តច្រើន, ស្តេចផែនដីដែលឯងចូលចិត្តចង់បានបុណ្យស័ក្តិអំពីព្រះអង្គ ទ្រង់មិនមែនសប្បាយចិត្តនឹងឯងឡើយ ៗ

— ឱលោកអើយ! ក៏ទាស់តែគ្មានវីរ៉ស៊ីនី បើគ្មាននាងហើយ ខ្ញុំក៏គ្មានចិត្តល្អទាំងអស់ បើមានវីរ៉ស៊ីនី ខ្លួនខ្ញុំមានព្រម ៗ គឺនាងហ្នឹងហើយជាកំណើត ជាជ័យមង្គល ជាសម្បត្តិរបស់ខ្ញុំ ៗ តែឪពុកបងប្អូនវីរ៉ស៊ីនី ចង់ឲ្យនាងមានប្តីនាហ្មឺនធំ ព្រោះគេបានជាអ្នកប្រាជ្ញ មានល្បីឈ្មោះ មកពីខំស្វឹងស្វាធ៍រៀនសូត្រ ខំអានគម្ពីរ, បើដូច្នេះ ខ្ញុំគិតចង់ទៅរៀនដូចគេដែរ ៗ បើខ្លួនខ្ញុំមានវិជ្ជាកាលណា ខ្ញុំនឹងជាមនុស្ស

មានប្រយោជន៍ដល់ផែនដីដោយពន្លឺ គឺបញ្ញានៃខ្ញុំ គ្មានធ្វើបាបដល់អ្នកណា គ្មានស៊ីដោយសារអ្នកណា ខ្ញុំទៅជាមនុស្សគ្រាន់បើមួយ ហើយសិរីសួស្ដីនឹងមានចំពោះខ្លួនខ្ញុំតែម្នាក់ឯង ។

— ឱកូន! អ្នកមានវិជ្ជាសឹងកម្រមាន ជាងអ្នកមានទ្រព្យនឹងមានជាតិ គឺវិជ្ជានេះហើយជាទ្រព្យយ៉ាងធំបំផុត ព្រោះគ្មានអ្នកណាអាចដកហូតយកបាន ហើយយើងទៅទីណាវិជ្ជាជាប់នឹងខ្លួនយើងទៅផង នឹងជាទីស្រឡាញ់នៃមហាជន តែវិជ្ជាថ្លៃណាស់ ។ គេស្វែងរកបានមកដោយការអត់ទ្រាំនឹងសការៈគ្រប់យ៉ាង ដោយចិត្តឈឺចាប់ជំរហ័សយ៉ាងសំខាន់ដែលធ្វើឲ្យមានសេចក្ដីលំបាកខាងក្នុងនឹងខាងក្រៅ ដោយមនុស្សផងគ្នាធ្វើទុកបុកម្នេញពេក ។ នៅប្រទេសបារាំង ពួកព្រះអង្គម្ចាស់មិនប្រាថ្នាល្បីឈ្មោះក្នុងការទាហានឡើយ ហើយមនុស្សជាច្រើនចូលចិត្តដើរតាមផ្លូវដែលឯងគិត ព្បិតគេចង់ឲ្យមានប្រាជ្ញាវាងវៃ ។ ឯងថាមកមើល តើឯងចង់បំរើមនុស្សលោកឬអ្វី? តែអ្នកណាមួយ កុំបាច់យកច្រើន តែសំណាបមួយគាប់ទៅដាំនឹងដី អ្នកឈ្មោះថាជាមនុស្សមានប្រយោជន៍ដល់មនុស្សផងគ្នាជាងឲ្យគម្ពីរមួយ ។

— អីស្រីដែលដាំដើមល្ហុងហ្នឹងឈ្មោះថា ហុចប្រយោជន៍ដ៏ល្អដល់មនុស្សជាតិក្នុងព្រៃជាងស្រីនោះធ្វើបណ្ណាល័យទៅទៀត ។

ក្នុងខណៈនោះ អាប៉ូលស្ទុះទៅឱបដើមល្ហុងហើយថើបដោយកាមភគចិត្ត ។

– បណ្ដាគម្ពីរទាំងឡាយ គម្ពីរដែលសំដែងពីសមភាព សិនេហភាព មនុស្សភាព សាមគ្គីធម៌និងច្បាប់នៃព្រះគ្រិស្ដ នាំបណ្ដាលជាហេតុឲ្យកើតក្ដៅក្រហាយអន្តរកម្បក្នុងប្រទេសអឺរុបអស់រយៈសតវត្សប៉ុន្មាន ។

" រឿងប្រកាប់ប្រចាក់ជាផ្លូវទុច្ចរិតដែលមានជាច្រើនតាំងពីដើមមកក៏នៅមានរហូតដល់សព្វថ្ងៃនេះ ។ បើដូច្នេះ អ្នកណាមួយនឹងចូលចិត្តខិតខំនូវគម្ពីរជាប្រយោជន៍ដល់មនុស្សក្នុងលោក! ឯងចាំប្ដូរទេ អ្នកប្រាជ្ញទាំងឡាយដែលសំដែងនូវធម៌សុចរិតហើយបានដល់នូវសេចក្ដីទុក្ខ យ៉ាងធំរហូតអស់ជីវិតក៏មាន? ។ ហោមែ (Homer) ជាអ្នកតែងកាព្យយ៉ាងល្បីឈ្មោះដើរសុំទានគេស៊ីទេ អស់មួយជីវិត ។ សូក្រាត (Socrate) ដែលជាអ្នកតែងពាក្យប្រៀនប្រដៅច្បាប់ទំនៀមទំលាប់ដ៏ល្អដល់អ្នកនគរ អាតេនី ស៊ីងស្លាប់ដោយគ្នាឯងបំពុល ។ លោកប្លាតុន (Planton) ជាសិស្សលោកសូក្រាតត្រូវលប់ទៅជាទាសៈគេ ព្រោះតែស្ដេចដែលទំនុកបំរុងលោក មុនលោកខាងលើនេះទៅទៀត មានអ្នកប្រាជ្ញម្នាក់ឈ្មោះពីតាគ័រ Pythagore) ត្រូវគេចាប់ដុតទាំងរស់មកតែពីការពោល ថាមនុស្សនឹងតិរច្ឆានមិនប្លែកគ្នាប៉ុន្មាន ។ បើយ៉ាងដូច្នេះតើឲ្យអញថាដូចម្ដេច? មានអ្នកប្រាជ្ញល្បីឈ្មោះ ជាច្រើនណាស់ទៀត ដែលបានទទួលនូវសេចក្ដីអន្តរាយបែបយ៉ាងនេះ តែគ្រាន់តែអំពើអកុសលខុសគ្នាប៉ុណ្ណោះ ។ ជាតិមនុស្សលោកប្រកបដោយចិត្ត អកតញ្ញូ ចូលចិត្តចង់ស្ដាប់អ្នកប្រាជ្ញទាំងនោះដែរ

អ្នកប្រាជ្ញណាមួយដែលផុតពីទុក្ខទោស លុះណាតែខ្លួនទៅនៅឆ្ងាយ
ពីពួកមនុស្សសាមញ្ញ ឬពីគ្នាឯង ។

"ឯងឃើញឬទេ បើចង់ឲ្យមានកេរ្តិ៍ឈ្មោះខាងអក្សរសាស្ត្រ ត្រូវឲ្យចិត្ត
ត្រឹមត្រូវស៊ូប្តូរជីវិតខ្លួន? ។ ម្យ៉ាងទៀត ឯងស្មានថាអ្នកមានសម្បត្តិនៅ
ឯប្រទេសបារាំងត្រូវការទិញវិជ្ជាហ្នឹងឬ? មិនដូច្នោះទេ គេអផ្សុកនឹងមនុស្ស
ចេះខាងអក្សរសាស្ត្រណាស់ ដ្បិតវិជ្ជាអក្សរមិនមាននាំមកនូវបុណ្យស័ក្តិ
ក្នុងព្រះនគរ ក្នុងផ្ទះរាជការ ឬនឹងនាំឲ្យបានធ្វើការងារក្នុងហ្នឹង ដល់
មនុស្សអ្នកចេះនោះសោះ ។ ក្នុងសតវត្សនេះ ពន្លឺគឺប្រាជ្ញានិងសេចក្តី
សុចរិតមិនមែនឲ្យប្រយោជន៍អ្វីឲ្យប៉ុកប៉ុន្មានទេ ព្រោះការរាជការក្នុង
ព្រះនគរសុទ្ធតែតម្លៃជាប្រាក់ អ្នកណាចង់ធ្វើរាជការ លុះតែមានប្រាក់
យកទៅសូកគេ ទើបបានការធ្វើ ។ ពីដើមវិជ្ជាអក្សរសាស្ត្រឲ្យប្រយោជន៍
ផ្សេងៗ ច្រើនក្នុងកិច្ចការខាងសង្ឃ ក្នុងតុលាការនិងរដ្ឋបាល សព្វ
ថ្ងៃនេះ ឲ្យប្រយោជន៍គ្រាន់តែសរសេរសៀវភៅទុកសម្រាប់ឲ្យគេអាន
ប៉ុណ្ណោះ ។ ហើយលទ្ធផលនេះ មិនសូវជាទីពេញចិត្តនៃមហាជនក៏ពិត
មែន តែគង់មានប្រយោជន៍ជានិច្ចតាមជាតិនៃវិជ្ជា ។ គម្ពីរទាំងឡាយនេះ
ជាពន្លឺដល់ទីងងឹត សម្រាប់លួងមនុស្សមានទុក្ខក្នុងប្រាណ បំភ្លឺជាតិ
ទាំងឡាយនាំឲ្យចេះនិយាយការពិត ទាំងស្តេចផែនដីក៏ដោយ ។ បើ
កុំយល់ទាស់ គឺទុកជាការវិភាពមួយដ៏សំខាន់ដែលទេព្តាទាំងឡាយគោង

មានចំពោះមនុស្សស្ថានកណ្ដាល ។ តើមនុស្សពួកណាដែលមិនសុខចិត្តនឹងការទុច្ចរិតនឹងសេចក្ដីមើលងាយ នៃជនទាំងឡាយជាអ្នកមានទ្រព្យ បើកាលណាគេដឹងប្រាកដថាស្នាដៃនៃខ្លួននឹងប្រព្រឹត្តទៅបាន ពីសតវត្សមួយទៅសតវត្សមួយ ពីសាសន៍មួយទៅសាសន៍មួយ សម្រាប់ផ្ដាប្រាដល់ចិត្តយល់គាន់ ដល់អ្នកកំណាចអាក្រក់ ហើយគេបញ្ចេញកេរ្តិ៍ឈ្មោះពីរហោស្ថានជាកន្លែងលំនៅនៃខ្លួនទៅរំលុបរំលាងកេរ្តិ៍ឈ្មោះ នៃព្រះរាជាទាំងឡាយដែលបានកសាងប្រាសាទធំ ៗ ជាវត្ថុតែងវិនាសទៅក្នុងអន្ទង់គឺការក្ចេប ទោះបីមានមនុស្សឧស្សាហ៍អួតសរសើរក៏ដោយ ។

– បើងចឹង ខ្ញុំចង់បានកេរ្តិ៍ឈ្មោះហ្នឹង ដើម្បីផ្សាយទៅលើវិស៊ុទីនឹងជាប្រយោជន៍ក្នុងលោកផង ។ តែអ្នកដែលចេះដឹងច្រើន ប្អូនអ្នកថាល្បងមើល តើយើងទាំងពីរនាក់នឹងបានគ្នាជាប្ដីប្រពន្ធឬទេ? ខ្ញុំចង់ធ្វើជាអ្នកប្រាជ្ញ ទោះបីម្ដេចម្ដា គ្រាន់នឹងស្គាល់ការណ៍ខាងអនាគត ។

– នែកូន ! អ្នកណាចង់រស់ ចាំបាច់តែស្គាល់អនាគតអី ! តែឲ្យដឹងសេចក្ដីទុក្ខមុន នាំឲ្យតែព្រួយឥតប្រយោជន៍, តែដឹងទុក្ខមុនប្រាកដ នាំឲ្យធ្វើទាស់ទទែងដល់ទៅថ្ងៃក្រោយទៀត ។ គេថែមទាំងមិនត្រូវគិតឲ្យសព្វគ្រប់ពេកផង អំពីរបស់ដែលនៅជុំវិញខ្លួន ។ ព្រះជាម្ចាស់ដែលបង្កើតឲ្យយើងចេះពិចារណា ដើម្បីសម្រាប់គ្រាន់គ្នានូវរបស់ត្រូវការ ហើយបង្កើតរបស់ដែលយើងត្រូវការ ដើម្បីជាទំនប់ដល់គំនិតយើង ។

– អ្នកថា នៅប្រទេសបារាំង តែមានប្រាក់ គេអាចរកបានបុណ្យស័ក្តិដោយងាយ ។ ខ្ញុំគិតទៅស្វែងទ្រព្យឯប្រទេសបេង្គាល (bengal) ឲ្យមានបរិបូណ៌ហើយនឹងរៀបការជាមួយវីរ៉ស៊ីនី ។ ខ្ញុំបង់គិតជិះកប៉ាល់ទៅស្អែក ។

– ម៉េច? អីឯងដើរចោលម្ដាយវីរ៉ស៊ីនី នឹងម្ដាយខ្លួនឯង? ។

– ចុះអ្នកទូន្មានខ្ញុំឲ្យទៅប្រទេសក្ងិគដើម្បីរកធនធាន ។

– កាលណោះ ដែលវីរ៉ស៊ីនីនៅក្នុងទីនេះ ។ ឥឡូវគឺឯងហ្នឹងហើយជាបង្គោលជាពំនឹងដល់ម្ដាយឯងនឹងម្ដាយនាង ។

– វីរ៉ស៊ីនី នឹងបញ្ជូនលុយកាក់មកចិញ្ចឹមលោកទាំងពីរបានដោយស្រួល ព្រោះបងប្អូនមានទ្រព្យ ។

– អ្នកមានទ្រព្យជួយចិញ្ចឹមខ្លួន លុះណាតែខ្លួនជួយលើកមុខគេនៅកណ្ដាលមហាជនផង ។ ខុះអីបងប្អូនគេ គួរឲ្យអាណិតជាងនាងឡាតួរទៅទៀត ហើយគ្មាននរណាជួយចិញ្ចឹម ស៊ូលះបង់ការសប្បាយទៅនៅសម្ងំក្នុងវត្តដើម្បីឲ្យរស់ខ្លួន ។

(មានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

លោក ជាប - ពិន ថ្លែងដាក់វិទ្យុប្រទេសកម្ពុជា នៅថ្ងៃទី ៣១ ; ១ ; ៥៣ ព. ស. ២៤៩៥

## ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

---

អស់លោក - អ្នកទាំងឡាយ !

ខ្ញុំបាទ បានទទួលកិត្តិយសមកប្រស្រ័យជាមួយអស់លោក - អ្នកទាំងឡាយដោយសំឡេងវិទ្យុប្រទេសកម្ពុជា ក្នុងនាមពុទ្ធសាសនបណ្ឌិត្យ រៀបរាប់អំពីសកម្មភាពរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលព្រះរាជរដ្ឋាភិបាលបានតាំងឡើងដើម្បីស្រាវជ្រាវនឹងរក្សាទុកនូវឯកសារ ស្ដីអំពីប្រពៃណីរបស់ខ្មែរយើងឲ្យគង់នៅ ជាឯកសារសម្រាប់ប្រទេសកម្ពុជាតទៅអនាគត ។

ឯវិធានការដែលក្រុមជំនុំទំនៀមទម្លាប់ខ្មែរបានចាត់ការមកហើយនោះ មានដំណើរដូចរៀបរាប់ជូន ដោយសង្ខេបតទៅនេះ :–

១ – ប្រឡងប្រជែងរាល់ឆមាសនៃឆ្នាំទីមួយៗ គឺ ៦ ខែប្រឡងម្ដងរវាងបេក្ខជនដែលស្ម័គ្រចិត្តប្រឡង ដើម្បីឲ្យបេក្ខជនទាំងនោះជូនឯកសាររឿងទំនៀមទម្លាប់ខ្មែរ ចំពោះរឿងណាដែលមិនទាន់មានបរិបូណ៌ដល់ក្រុមជំនុំ តាមដែលក្រុមជំនុំត្រូវការស្រាវជ្រាវរក ។

២ – ស៊ើបសួរយកការរឿងទំនៀមទម្លាប់ខ្មែរ ចំពោះសមាជិកឆ្លើយឆ្លងក្នុងខេត្តនិងស្រុកនានា ដែលក្រុមជំនុំបានតាំងប្រចាំការសម្រាប់

សាកសួរ ដោយបានឲ្យសមាជិកឆ្លើយឆ្លងទាំងនោះ សរសេរឯកសារ ផ្សេងៗឲ្យការជារឿយៗ ។

ពួកវិញ្ញូជនដែលយល់ច្បាស់នូវឧត្តមប្រយោជន៍ របស់ក្រុមជំនុំនេះ បានចុះឈ្មោះជាបេក្ខជន និងសមាជិកឆ្លើយឆ្លងជាច្រើនរូប បានសរសេរ ឯកសារទំនៀមទម្លាប់ផ្សេងៗ ផ្ញើទៅប្រឡងនិងឲ្យការទៅក្រុមជំនុំ ។

ខាងការប្រឡងប្រជែង.— កាលដល់ចុងឆមាសនីមួយៗ ក្រុមជំនុំ បានជួបជុំពិនិត្យឯកសាររបស់បេក្ខជនទាំងនោះ, ឯកសារដែលល្អៗ បាន ឲ្យជាប់តាមថ្នាក់ បានជូនរង្វាន់ ដូចក្នុងប្រកាសដែលជូនដំណឹងជាមុន ។

ខាងការសមាជិកឆ្លើយឆ្លង.— កាលដល់ចុងឆមាសនីមួយៗ ក្រុមជំនុំបានយកឯកសារផ្សេងៗ របស់សមាជិកទាំងឡាយមកពិនិត្យ ហើយបានជូនរង្វាន់តាមថ្នាក់ល្អអាក្រក់របស់អ្នកឲ្យការ និងតាមចំនួន ឯកសារតិចច្រើន ។

ចំពោះឆមាសទី ២ នៃឆ្នាំ ១៩៥២ ដែលក្រុមជំនុំបានបាត់វិធានការ ប្រឡងប្រជែង ២ រឿង គឺទំនុកច្រៀងបុរាណរបស់ខ្មែរ ១ រឿង, មហោស្រពខ្មែរ ១ រឿង នោះបានលទ្ធផលដូចតទៅនេះ :-

រឿងទំនុកច្រៀងបានជាប់ ៣ រូប គឺ

– លោក គង់-ចន្ទូន: នៅឃុំជ្រៀន ស្រុកព្រៃឈរ ខែត្រ កំពង់ចាមបានជាប់លេខ ២ ត្រូវបានរង្វាន់ជាប្រាក់ ១៥០រ,០០ ។

- លោក សោម-ហុម ក្រឡាបញ្ជីរ៉ែត នៅខាងលិចសាលារចនា ភ្នំពេញ បានជាប់លេខ ៤ ត្រូវបានរង្វាន់ជាប្រាក់ ១០០៛,០០ ។

- លោក កូ-តាកែ ស្មៀនឃុំ ឃុំអន្លង់គ្នាត ស្រុកក្រគរ ខេត្តពោធិសាត់ បានជាប់លេខ ៤ ត្រូវបានរង្វាន់ជាប្រាក់ ១០០៛,០០ ។

រឿងមហោស្រពចាងជាប់ ១រូប គឺ

- លោក សោម-ហ៊ុម ក្រឡាបញ្ជីរ៉ែត នៅខាងលិចសាលារចនាក្រុងភ្នំពេញ បានជាប់លេខ ៣ ត្រូវបានរង្វាន់ជាប្រាក់ ១២០៛,០០ ។

ការប្រឡងលើកនេះគ្មានជាប់រង្វាន់លេខ ១ទេ ដោយមិនមានឯកសារដែលគួរឲ្យជាប់ថ្នាក់នោះបាន ។

សេចក្ដីប្រកាសលទ្ធផលនៃការប្រឡងដូចរៀបរាប់មកនេះ ទុកជាការប្រកាសកិត្តិយសរបស់បេក្ខជនដែលបានយកចិត្តទុកដាក់ ធ្វើការបំពេញកិច្ចរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលជាក្រុមស្រាវជ្រាវរក្សាទុកនូវអារ្យធម៌របស់ប្រទេសជាតិឲ្យបានបម្រើន ។

សេចក្ដីប្រកាសផលលទ្ធផលបែបនេះ ក្រុមជំនុំបានផ្សាយក្នុងវិទ្យុ នឹងសារពត៌មានកម្ពុជា រាល់ការៈដែលប្រឡងជាប់គ្រប់ឆមាសនីមួយៗ រៀងរាល់ឆ្នាំ ។

ក្នុងឆមាសទី ១ ខាងដើមឆ្នាំ ១៩៥៣ នេះ ក្រុមជំនុំនឹងប្រកាសបើកប្រឡង ២ រឿងទៀត គឺរឿងទី ១ អំពីភ្ជាប់ពាក្យស៊ីស្លា, រឿងទី ២

អំពីភ្លើង ៗ ការប្រឡងលើកនេះមានបន្ថែមរង្វាន់ច្រើនលើសមុន ដូចមានប្រកាសផ្សាយខ្លះទៅហើយ សូមអស់លោកវិញ្ញូជនទាំងឡាយ សរសេរឯកសារដូចជម្រាបខាងដើមផ្ញើទៅប្រឡងឲ្យបានច្រើន ដើម្បីឲ្យបានចម្រើនឯកសារអារ្យធម៌ខ្មែរយើងតទៅ ៗ

ផ្នែកសមាជិកឆ្លើយឆ្លង ក្រុមជំនុំបានស្រង់យកនាម និងកិច្ចការរបស់សមាជិកខ្លះ មកផ្សាយក្នុងវិទ្យុ និងចុះក្នុងសារពត៌មានកម្ពុជាពីមុនខ្លះរួចមកហើយ ជាការប្រកាសកិត្តិយសរបស់សមាជិកទាំងឡាយដែលបានជួយធ្វើការក្រុមជំនុំ ៗ

វេលានេះ ក្រុមជំនុំសូមប្រកាសកិត្តិយស របស់សមាជិកឆ្លើយឆ្លងខ្លះទៀត ចំពោះនាមនិងកិច្ចការ ព្រមទាំងឯកសាររបស់សមាជិកខ្លះដែលពុំទាន់បានផ្សាយនៅឡើយ ៗ

ក្រុមជំនុំមានអំណរណាស់ ចំពោះការដែលអស់លោកជាសមាជិកឆ្លើយឆ្លងបានឲ្យការនោះ តែសូមជម្រាបថា ឯកសារដែលអស់លោកបានឲ្យមកនោះ មានច្រើន ដែលក្រុមជំនុំពុំអាចយកមកថ្លែងដំណាលគ្នាក្នុងពេលនេះបាន ៗ ដូច្នេះ បើមិនឃើញមាននាមក្នុងទីនេះ សូមអស់លោកកុំឆ្ងល់ ព្រោះក្នុងទីនេះក្រុមជំនុំជ្រើសយកចំពោះតែនាមសមាជិកនិងឯកសារដែលបានទទួលពីត្រឹមខែមករា ខែកុម្ភៈ និងខែមីនា ឆ្នាំ ១៩៥២ ហើយនិងចំពោះឯកសារដែលអ្នកសរសេរឲ្យការ បានប្រាប់គោលប្រាប់ដើមកំណើតច្បាស់លាស់ ៗ

ឯនាមទឹងឯកសាររបស់សមាជិកផ្ញើយចូន ដែលត្រូវយកមកថ្លែងក្នុងវេលានេះ ដូចរៀបរាប់តទៅនេះ :-

លោក សាំង-លិន នៅឃុំល្វេ ស្រុកស៊ុធរកណ្ដាល ខេត្តព្រៃវែង បានឲ្យឯកសាររឿងទំនៀមទម្លាប់ផ្ទាក់ក្បាលដំណើរផ្ទះ ជារូបក្បាលសេះ លោកថាគេផ្ទាក់រូបនេះដើម្បីការពារដម្រីអារក្សកូន ទឹងដម្រីចូន តាមជំនឿរបស់អ្នកស្រុក ។ លោកនេះបានបញ្ជាក់ដើមកំណើតឯកសារនេះថា "លោកបានដឹងទំនៀមនេះ អំពីសំណាក់ឈ្មោះព្រាប-ប៊ុត នៅឃុំល្វេ ស្រុកស៊ុធរកណ្ដាល ខេត្តព្រៃវែង" ។

ចំពោះការធ្វើដំណើរ លោក សាំង-លិន បានឲ្យការថា "សម័យបុរាណ អ្នកស្រុកមុននឹងធ្វើដំណើរទៅទីណា ៗ ទោះផ្លូវទឹកក្ដី គោកក្ដី តែងមើលពេលល្អអាក្រក់ ថ្ងៃលិចអណ្ដែត ទឹងដង្ហើមរស់ដង្ហើមស្លាប់" ។ ថា "លោកបានចម្លងក្បួននេះ តាមក្បួនខ្ទង់រ៉ង់ខុគ្គង់ចម្លែក ជាក្បួនមើលពេលាគ្រប់យ៉ាងល្អិតល្អណាស់" ប៉ុន្តែចាស់តែលោកនេះពុំបានប្រាប់ដើមកំណើតថាក្បួននេះរបស់អ្នកណានៅទីណាឡើយ, បើប្រសិនជាលោកនេះប្រាប់ដើមកំណើតក្បួននេះផង នោះជាការគាប់ប្រសើរណាស់ ។

រឿងនេះ ក្រមជំនុំស្រាវជ្រាវរកឃើញក្នុងសេចក្ដីកត់ហេតុរបស់អ្នកដំណើរជាតិចិនម្នាក់ឈ្មោះ ជាវ-តាក្វន ដែលបានមកកាន់ប្រទេសខ្មែរយើងក្នុងសតវត្សរ៍ទី ១៣ (រវាងពី គ.ស. ១២៩៥ ទៅ ១២៩៧) បានធ្វើ

សេចក្តីរាយការណ៍អំពីទំនៀមទម្លាប់ខ្មែរក្នុងសម័យនោះចំនួន ៤០ មាតិកា; ត្រង់មាតិកា ទី ១១ និយាយដល់ "ទំនៀមការធ្វើដំណើរ" របស់ប្រជាជនជាតិខ្មែរយើងថា "សម័យនោះ ខ្មែរចេះក្បួនហោរាសាស្ត្រយ៉ាងជំនាញ អាចព្យាករណ៍អំពីចន្ទគ្រាះ និងសូរ្យគ្រាះបានច្បាស់លាស់;... ថា "ខ្មែរជាន់នោះមានទំនៀមប្រកាន់ថ្ងៃល្អ-អាក្រក់ (លិចអណ្តែត) សូម្បីតែគេដើរទៅទិសខាងកើត ឬទិសខាងលិចក៏មានរាប់ថ្ងៃលិច ថ្ងៃអណ្តែតជាដរាប ។ របៀបនេះ សូម្បីស្រីៗ ក៏ចេះដែរ"... ជាន់នោះ ។

លោកគ្រូពុទ្ធសិរី ចាប-ចន្ទ វត្តក្តីក្រៅ ឃុំខ្នារស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បានឲ្យសាវតារស្រុកខ្មែរ ។ ក្នុងសាវតារនេះបានឲ្យការ ១ កន្លែង ថាកាលពីដើមព្រះថោងបានយកគង់ ១ ទៅកប់ក្រោមដើមធ្លក ធ្វើឧបាយដើម្បីនឹងដណ្តើមយកនគរពីព្រះបាទអស្សវៃពជ ។ កាលបរិវារក្រាបបង្គំទូលសួរថា "ទ្រង់គិតឲ្យសង់ព្រះរាជដំណាក់នៅទីណា?" ទ្រង់តបថា "ធ្វើឯណាកើតបើកំពង់ក្តីគ្នា" ។ ព្រោះហេតុដូច្នេះបានជាជាប់ឈ្មោះថាកំពង់ក្តីដរាបមកដល់សព្វថ្ងៃនេះ (នៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប) ។

លោកគ្រូអង្គនេះបានឲ្យដើមកំណើតនំបញ្ចុកថា នំបញ្ចុកមានឈ្មោះដើម ៤ យ៉ាង គឺទី ១ ហៅនំនាងវែង, ទី ២ ហៅនំសរសៃវែង, ទី ៣ ហៅនំស្រុកខ្មែរ, ទី ៤ ហៅនំធនញ្ជ័យ ។ បានជាហៅដូច្នេះ ព្រោះនំនេះធនញ្ជ័យនៅស្រុកខ្មែរយើង បានផ្តើមធ្វើជាដំបូងថ្វាយស្តេចក្រុងចិននៅ

ស្រុកចិន ដែលមានព្រះភក្ត្រដូចសុនខ ព្រោះសុនខឈ្មោះអាមៅនៅស្រុកខ្មែរយើងទៅចាប់កំណើត, ស្តេចនោះបើអ្នកណាហ៊ានងើបមើលចំព្រះភក្ត្រទ្រង់ៗ ឲ្យយកអ្នកនោះទៅសម្លាប់; ធនញ្ជ័យចង់មើលព្រះភក្ត្រទ្រង់ ទើបផ្ដើមធ្វើនំសរសៃវែងៗ យកទៅថ្វាយ ។ ស្តេចស្រុកចិនឲ្យធនញ្ជ័យភ្លក្សមើលមុន វេលាភ្លក្សធនញ្ជ័យយកដៃកាន់សរសៃនំវែងបញ្ចុកកងមាត់ ងើបមើលមុខឡើងក្លែកលបសំឡឹងមើលព្រះភក្ត្រស្តេចក្រុងចិន, ហេតុនេះបានជាជាប់ឈ្មោះថានំបញ្ចុកតាំងពីពេលនោះមក ។

លោក អុង-គិមហ៊ាន ស្មៀនប៉ុយរ៉ូភូមិបាល ស្រុកសង្កែ ខេត្តបាត់ដំបង បានឲ្យឯកសារក្បួនសង់ផ្ទះរបៀបខ្មែរបុរាណ ដែលមានរៀបរាប់ពីរបៀបធ្វើភូមិ ធ្វើផ្ទះ រហូតដល់ធ្វើគ្រែដោយសព្វគ្រប់ល្អិតល្អណាស់ ។

ក្រុមជំនុំបានទទួលឯកសាររឿងសង់ផ្ទះច្រើនបែបប្លែកៗគ្នា ប៉ុន្តែលោកនេះ បានយល់ពាក្យសំនួរយើងសព្វគ្រប់ លោកបានបញ្ជាក់ដើមកំណើតនៃក្បួនសង់ផ្ទះនេះ ថាលោក បានចម្លងត្រឹមត្រូវតាមក្បួនដើមរបស់លោកតាអាចារ្យពាន់នៅភូមិជាប់របង់វត្តអញ្ចាញ ឃុំបុស្សក្រោក ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។

លោក ជូ-អ៊ុក ប៊ូងតុងសាលាខេត្តតាកែវ បានឲ្យឯកសាររឿងជម្ងាញខ្មែរ ។ យើងសូមអរគុណលោកនេះ ដោយលោកបានពន្យល់ច្បាស់លាស់អំពីគំត្បាញខ្មែរ ថែមទាំងគូរគំនូរពន្យល់អំពីជម្ងាញ ទីងប្រដាប់ប្រើក្នុងការត្បាញបែបខ្មែរយើងផង ។

បើប្រសិនជាលោកនេះ អធិប្បាយអំពីរបៀបដែលក់ត់ណារបៀបប្រើសំពត់ហូលផ្សេងៗ និងដើមកំណើតសំពត់ចបុចផងទៀត នោះជាការល្អណាស់ ព្រោះជាការដែលពុំសូវមានអ្នកណាឲ្យការមកក្រុមជំនុំ ហើយក្រុមជំនុំកំពុងតែស្រាវជ្រាវរកដើមកំណើតការនោះផង ។

សេចក្ដីនេះ យើងចង់បង្ហាញឲ្យឃើញថា ឯកសាររឿងទំនៀមទម្លាប់អ្វីរបស់ខ្មែរ យើងក៏ត្រូវការដែរ ឲ្យតែមានដើមកំណើត ហើយអធិប្បាយឲ្យសព្វគ្រប់ល្មមយកជាការបាន ។ មួយយ៉ាងទៀត ដល់ទៅអនាគត លុះអារ្យធម៌របស់ខ្មែរយើងកាន់តែចម្រើនឡើង ខ្មែរយើងនឹងភ្លេចអារ្យធម៌ខ្មែរសម័យបុរាណអស់ ។ ឯកសារដែលយើងប្រមូលទុកសម័យនេះហើយ ដែលអាចនឹងបំភ្លឺដល់អ្នកសម័យក្រោយនោះបាន ដូចសម័យបច្ចុប្បន្នដែលយើងស្រាវជ្រាវរករឿងរ៉ាវ អំពីប្រាសាទនគរវត្តសម័យបុរាណនោះដែរ ។

នៅទីបំផុតនេះ ក្រុមជំនុំសូមអំពាវនាវដល់អស់លោកអ្នកស្ដាប់អ្នកអានទាំងឡាយ ដែលធ្លាប់បានស្ដាប់ បានឃើញ បានចេះចាំនូវប្រពៃណីខ្មែរសូមចណ្ណៈឆន្ទៈដ៏ល្អនឹករលឹកដល់ការចេះចាំ ហើយសូមសរសេរឯកសាររឿងទំនៀមទម្លាប់ខ្មែរណាមួយ តាមដែលអស់លោកពេញចិត្តឲ្យការទៅក្រុមជំនុំ ដើម្បីទុកជាគ្រឿងនៅមន្ទីរទុកឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ជាប្រយោជន៍របស់ជាតិនឹងជាគោលតារិកប្រទេសតទៅ ។

ក្រុមជំនុំសូមទទួលអំណរគុណយ៉ាងខ្ពស់ចំពោះអស់លោកទុកជាមុន ។

## សុន្ទរកថា

# លោកដុកទ័រគុណបលៈបិយៈសេនៈម៉ាល៉ាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២
នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

## ពុទ្ធសាសនបណ្ឌិត្យ

(តមក)

ត្រូវញ៉ាំងឲ្យក្មេងទាំងនោះ រស់នៅក្នុងយុវនភាពប្រកបដោយបរិយាកាសផ្សាយចេញពីឧត្តមគតិនៃព្រះធម៌ ដែលធ្វើឲ្យក្មេងទាំងនេះស្ថិតនៅរឹងប៉ឹងក្នុងជំនឿព្រមទាំងមានសទ្ធាដោយក្លាហាន ដើម្បីជាទិដ្ឋានុគតិចំពោះសាសនារបស់ខ្លួន ៗ ក្មេងទាំងនេះអាចប្រព្រឹត្តនូវគុណធម៌ពីរយ៉ាង គឺករុណា នឹងប្រាជ្ញាដែលជាមូលដ្ឋាននៃពុទ្ធោវាទ ៗ យើងក៏មិនត្រូវភ្លេចដែរនូវការសិក្សានៃក្មេងជំទង់ ព្រមទាំងក្មេងដែលមានរូបកាយវិកលវិការសោះឡើយ ៗ នៅប្រទេសខ្លះ ដែលអប់រំព្រះពុទ្ធសាសនា, រដ្ឋាភិបាលបានណែនាំសាលាគ្រហស្ថខាងថ្នាក់កុមារដ្ឋាន ដោយមិនគិតដល់វិជ្ជាជីវៈ ហើយការសិក្សាខាងសាសនាមិនបានយកទៅបញ្ចូលក្នុងកម្មវិធីនៃការសិក្សាសោះឡើយ ៗ ទាំងនេះមកពីបំណងអ្នកកាន់អំណាច មិនចង់ឲ្យមានគ្រោះថ្នាក់ឥតប្រយោជន៍ ៗ តែមាន ព្រឹត្តិការណ៍ថ្មី ដែលកើត

ឡើងពាសពេញ បញ្ជាក់ឲ្យឃើញច្បាស់លាស់ថា បុរសនិងស្ត្រីដែលចម្រើនវ័យធំឡើង គ្មានឧត្តមគតិខាងសាសនា នាំឲ្យមានភ័យដល់សន្តិភាព និងសុភមង្គលនៃពិភពលោក ។ ព្រោះហេតុដូចនេះ គឺថាត្រូវមានករណីយកិច្ចដ៏ប្រសើរ ចំពោះរដ្ឋាភិបាល ដែលត្រូវទទួលការខុសត្រូវខាងការសិក្សាជាសាធារណៈ រៀបចំអង្គការឲ្យកូនសិស្ស បានសិក្សារៀនសូត្រហើយដល់ចេញពីសាលា ត្រូវមានបំណោះគ្រប់គ្រាន់ខាងសាសនា ដែលបានអប់រំតាំងពីកំណើតមក ។ ខ្ញុំមានសោមនស្សរីករាយពន់ពេកដោយខ្ញុំបានពោលថា នេះហើយជានយោបាយដែលរដ្ឋាភិបាលសេរីនៃប្រទេសខ្ញុំ គឺកោះស៊ីឡង់ត្រូវប្រព្រឹត្ត ប្រតិបត្តិតាម ។ គឺជាទិដ្ឋានគតិគួរយកតម្រាប់តាមចំពោះអ្នកទាំងអស់គ្នា ដែលមានបំណងឲ្យអ្នករស់នៅក្នុងអនាគតកាលបានសេចក្ដីសុខ ។

## ព្រះសង្ឃ

ចំពោះកិច្ចការខាងសិក្សា ហើយនិងការញុំាងឲ្យសង្គមចម្រើន, មុខការសំខាន់នេះ គឺត្រូវព្រះសង្ឃកាន់កាប់ ។ សូម្បីតែត្រង់ទឹកដីដែលធំទូលាយសម្បូណ៌ដោយទាយកទាន ចំពោះការធ្វើយកកម្រៃខ្លួនឯង ព្រះសង្ឃក៏ត្រូវយកគ្រហស្ថជាទីពឹងផ្អែក ។ ខ្ញុំសូមបន្ថែមទៀតថា ទាយកទានទាំងនេះជារបស់គ្រួណាស់ ហើយពួកសមាជិកខាងព្រះសង្ឃចំពោះប្រទេសដែលខ្ញុំស្គាល់ ក៏ត្រូវពឹងផ្អែកទៅលើគ្រហស្ថទាំងអស់ ។

បំណែកកិច្ចការ ដែលត្រូវការពល់ថ្ងៃក៏ដូចនោះដែរ ។ គឺជាករណីយកិច្ចជាដំបូង ដែលត្រូវយើងគិតចំពោះព្រះសង្ឃត្រង់ការធ្វើឲ្យព្រះសង្ឃបានសុខស្រួល ។ ត្រូវធ្វើសម្ពន្ធមិត្តកិច្ចជានិរន្តរ៍នឹងព្រះសង្ឃ ដើម្បីនឹងញ៉ាំងសកម្មភាពខាងសាសនា ឲ្យប្រព្រឹត្តទៅ ។ យើងមិនត្រូវភ្លេចថាព្រះសង្ឃជាអ្នករក្សាទុក នូវគម្ពីរសាស្ត្ររបស់យើង បន្ទុមនូវកេរ្តិ៍មរតកនៃអក្សរសាស្ត្រខាងសាសនា ព្រមទាំងរក្សាទុកនូវសភាពបរិសុទ្ធស្អាតនៃសាសនាក្នុងពេលកលិយុគនៃប្រវត្តិសាស្ត្រ ។ ថ្ងៃណាដែលព្រះសង្ឃធ្លាក់ចុះវិនាសបង់, ថ្ងៃនោះសាសនាយើងក៏រលត់ ។

បើយើងពិនិត្យនូវស្ថានការណ៍បច្ចុប្បន្ននៃព្រះសង្ឃ មានរឿងរ៉ាវជាច្រើនបែបដែលយើងយល់ថា គួរយកមកពណ៌នាក្នុងទីនេះ ។ ព្រោះហេតុដូចនេះយើងមិនត្រូវយល់ថា មិនពិត ត្រង់ការបាក់បែកជាខ្លាំងចំពោះព្រះសង្ឃនឹងគ្រហស្ថ ឥឡូវនេះយើងឃើញថា ព្រះសង្ឃមិនមែនជាមគ្គុទ្ទេសក៍, អ្នកទស្សនវិទូនឹងជាអ្នកកល្យាណមិត្តនៃគ្រហស្ថដូចពីអតីតកាល ។ ត្រូវចាត់ចែងការពីរយ៉ាងក្នុងមួយរំពេចដើម្បីនឹងការពារនូវសភាវៈបែបនេះ កុំឲ្យមានតទៅអនាគតទៀត គឺៈ–

ទី ១ ត្រូវស្ថាបនានូវសាលាគរុវិជ្ជា ចំពោះសង្ឃសមាជិក ដែលគេត្រូវបង្ហាត់បង្រៀនមិនត្រឹមតែអត្ថបទនៃព្រះពុទ្ធសាសនាទេ ថែមទាំងកិច្ចការស្រាវជ្រាវសម័យបច្ចុប្បន្ន នូវវិទ្យាសាស្ត្រព្រមទាំងភាសាទំនើប

ដែលជាហេតុឲ្យព្រះសង្ឃទាំងនោះ បើកនូវប្រាជ្ញាឲ្យបានភ្លឺស្វាងរុងរឿង ចំពោះកិច្ចការដែលមានជុំវិញក្នុងពិភពលោក ។ បើគ្មានចំណេះទាំងនេះទេ ព្រះសង្ឃមិនអាចនឹងធ្វើឲ្យយើងគោរពកោតខ្លាច ឬ ប្រគេនមុខការទាំងត្រួតត្រានូវបញ្ហាជីវភាព ដែលធ្លាប់មានមកក្នុងមួយថ្ងៃៗ ។ ម្យ៉ាងវិញទៀត ការដែលអប់រំបែបនេះនាំឲ្យព្រះសង្ឃទាំងនោះ មានសមត្ថភាពត្រង់ធ្វើពុទ្ធបេសកកម្មឲ្យបានផលល្អ ចំពោះប្រទេសទាំងនោះ ដែលមិនទាន់ស្គាល់ព្រះពុទ្ធសាសនាច្បាស់លាស់ ព្រមទាំងផ្សាយព្រះពុទ្ធសាសនាឲ្យជ្រួតជ្រាបទៅក្នុងប្រជាជនទាំងអស់ ព្រមទាំងប្រយោជន៍នៃវិជ្ជា, សទ្ធាដ៏ក្លាហាននឹងការពិសោធន៍ថ្មីថ្មារបស់ព្រះសង្ឃទាំងនេះ ។

ទី ២ ពួកគ្រហស្ថត្រូវប្រស្រ័យគ្នាជាមួយនឹងព្រះសង្ឃ, ដែលជាគ្រូខាងប្រាជ្ញា ដោយត្រូវទៅកាន់វត្តអារាមមិនត្រឹមតែធ្វើបុណ្យ ថែមទាំងធ្វើឯទៀតផង ។ វត្តអារាមនេះ ត្រូវត្រឡប់ទៅជាមជ្ឈដ្ឋានសកម្មភាពខាងព្រះពុទ្ធសាសនា ព្រមទាំងពួកសង្ឃសមាជិកនឹងចៅអាវាសវត្តពិតឬមានតែងតាំងតាមច្បាប់ត្រឹមត្រូវ ។ ត្រូវទទួលកំហុសចំពោះពួកយើងដោយភាគច្រើន, គឺកិច្ចការដែលទៅវត្តនោះរយាលពន់ពេកហើយ, បើនឹងបានទៅ ក៏ទៅដើម្បីថ្វាយបង្គំព្រះ ហើយសូត្រធម៌ទៅតាមគាថាព្រះសូត្រ ដែលយើងមិនស្គាល់ន័យថែមទៀតផង ។ កិច្ចការដែលប្រព្រឹត្តបែបនេះមិនសមរម្យទៅតាមវិចារណញ្ញាណ ត្រូវតែបោះបង់

ហោលចេញ ។ ប៉ុន្តែចំពោះយើងជាពុទ្ធសាសនិកជន ថ្ងៃសប្ដាហៈដែលបានប្រកាសជាផ្លូវការថា ជាថ្ងៃឈប់សម្រាកសិន ត្រូវគ្មានថ្ងៃដែលសាសនាបានបញ្ញត្តិឲ្យឈប់ ហើយយើងបានប្រើពេលវេលានោះក្នុងអកម្មកភាព ឬក្នុងកិច្ចស្វែងរកនូវការសប្បាយក្នុងអាមិស ។ ព្រោះហេតុដូចនេះបានជាយើងមិនអាចកំណត់ឈប់ទៅតាមថ្ងៃបុណ្យ ក្នុងសាសនា. ដែលយើងនឹងប្រតិបត្តិប្រពៃណីនិយមរបស់យើង ។ មានប្រទេសខ្លះដូចជាប្រទេសស៊ុយអ៊ែដ ចំពោះរដ្ឋាភិបាលគេហ៏ស្ដូបានទទួលស្គាល់នៅថ្ងៃនេះ ដែលមានសារសំខាន់ៗ ខាងពុទ្ធសាសនា ហើយថ្ងៃទាំងនោះ គេទុកជាថ្ងៃបុណ្យតាមផ្លូវការ, តែអ្វីក៏មិនអាចផ្លាស់ប្ដូរបាន នូវការទស្សនាសប្ដាហៈ ឯទីវត្តអារាម ដែលអាចប្រព្រឹត្តទៅបាន ចំពោះបុរាណនិយម ។ គឺជាបញ្ហាមួយយ៉ាងសំខាន់បំផុត ដែលយើងត្រូវពិនិត្យយ៉ាងម៉ឺងម៉ាត់ តទៅអនាគត ។

កិច្ចដែលត្រូវការខានមិនបាន ក្នុងការស្ថាបនានូវបូជនីយដ្ឋានដែលពួកពុទ្ធសាសនិកជនអាចនឹងអញ្ជើញទៅធ្វើនមស្សការបូជាចំពោះខ្លួន ឬច្រើនគ្នា ហើយការធ្វើនូវបូជនីយដ្ឋាននេះ ដើម្បីនឹងផ្សាយនូវព្រះធម៌ នាំឲ្យកើតបញ្ហាមួយ គឺការស្ថាបនានូវប្រទេសជាច្រើន មានបច្ចិមប្រទេសជាដើម ។ បញ្ហានេះ ពុទ្ធសាសនិកជនខាងទ្វីបអឺរ៉ុប បានពិនិត្យជាយូរណាស់មកហើយ ហើយមានខ្លះពោលថា មិនមានមធ្យោបាយ

អ្វីដែលនឹងរិះរកនូវប្រាក់ចំណាយដើម្បីនឹងស្ថាបនា ព្រមទាំងថែទាំរក្សាទុកនូវមជ្ឈមណ្ឌលនេះ នេះជាពេលឱកាសដ៏ល្អ ដែលពួកសុទ្ធបុគ្គលខាងព្រះពុទ្ធសាសនានៃប្រទេសក្នុងទ្វីបអាស៊ី ដោយបុញ្ញាធិធី ដោយធ្វើអំណោយនូវព្រះធម៌ ដែលតាមព្រះបរមពុទ្ធោវាទ មានសភាពឧត្តមផុត ។ ខ្ញុំសូមរំលឹកអ្នកអំពីសេចក្តីស្នើនូវការសង់ព្រះវិហារមួយ នៅទីក្រុងឡុងដ៍ដែលជាមជ្ឈមណ្ឌល បំពោះប្រទេសនៃអឺរុបខាងលិច ។ ព្រះសង្ឃដែលនឹងត្រូវណែនាំមជ្ឈមណ្ឌលនោះ រង់ចាំនូវមធ្យោបាយផ្សេងៗ ក្នុងការនោះ ។ វិធានខាងព្រះពុទ្ធសាសនា គឺការស្ថាបនានូវព្រះសង្ឃក្នុងប្រទេសនីមួយៗ ដែលមានពួករដ្ឋវាសីជាសមាសភាព, មានឥស្សរភាព ត្រង់គ្មានអ្នកក្រៅទៅត្រួតត្រាបាន គឺព្រះសង្ឃទាំងនេះមានករណីយកិច្ចតែប្រព្រឹត្តទៅតាមវិន័យពុទ្ធសាសនាប៉ុណ្ណោះ ។ ព្រោះហេតុដូចនេះ គួរតែយោបល់បែបនេះ, ពួកប្រជាជនខាងទ្វីបអឺរុបនឹងអាមេរិកយកតម្រាប់តាម, តែដើម្បីនឹងរង់ចាំ ឲ្យយោបល់ទាំងនោះមានសភាពពិតមែន, ត្រូវតែចាត់ព្រះសង្ឃជាច្រើន ទៅកាន់ប្រទេសដែលកាន់ព្រះពុទ្ធសាសនា ។ ខ្ញុំអាចបន្ថែមបានថា ព្រះសង្ឃទាំងនេះត្រូវជ្រើសរើសចំពោះព្រះសង្ឃដែលមានចរិយាត្រឹមត្រូវ ។ ខ្ញុំមិនអាចពណ៌នាឲ្យវែងឆ្ងាយតទៅទៀត អំពីរឿងនេះដែលមានមកក្នុងពេលសន្និសីទនេះ ។ តែដើម្បីនឹងរង់ចាំឱកាសដ៏ល្អទៅថ្ងៃក្រោយ, យើងត្រូវឧបត្ថម្ភ ទៅពួកក្រុមខាងព្រះពុទ្ធសាសនា ដែលស្ថិតនៅក្នុងប្រទេសខាង

អឺរ៉ុបនិងអាមេរិក មានប្រទេសខ្លះមានបែកយោបល់គ្នា ចំពោះបញ្ហាភូមិសាស្ត្រនិងភាសាសាស្ត្រ. ពិតមែនតែមានប្រទេសខ្លះបានរក្សាសម្ពន្ធកិច្ចនិងក្រុមដែលស្គាល់ ។ គឺយើងត្រូវជួយពួកក្រុមដែលនៅឃ្លាតឆ្ងាយពីយើង ដោយប្រស្រ័យគ្នាទៅវិញទៅមក ។ នេះជាវត្ថុបំណងនៃសមាគមយើង ។ ព្រោះនៅក្នុងក្រុមទាំងនោះ គឺមានប្រាថ្នាចង់ជួយគ្នាដោយចិត្តស្មោះស្ម័គ្រប៉ុណ្ណោះ ។ ព្រោះហេតុដូចនេះ ជាករណីយកិច្ចខានមិនបាន ចំពោះពួកក្រុមទាំងនោះ និងពួកពុទ្ធសាសនិកជន, ត្រូវធ្វើសម្ពន្ធកិច្ចជាញឹកញយ និងអង្គការកណ្ដាលមួយដូចជាសមាគមយើង ។ ពិតមែនតែសមាគមនេះធ្វើការដោយលំបាក, ហើយទើបនឹងដំណើរការដំបូងក៏គង់បានផ្ដើមធ្វើការគមនាគមន៍ហើយ ស្ថិតនៅក្នុងការប្រស្រ័យជានិរន្តរ៍ចំពោះពួកក្រុមនិងពួកជនពិសេស ក្នុងភូមិភាគនៃពិភពលោក, មានខ្លះស្ថិតនៅទីឆ្ងាយក៏មាន ។ ព្រោះហេតុដូចនេះយើងត្រូវតែធ្វើតុល្យការអំពីសារសំខាន់ និងដំឡៃនៃលិខិតសួរឆ្លើយរវាងជាតិដែលយើងបានដឹងថា មានប្រយោជន៍កើតកាលវេលា ។ ក្នុងសម័យបច្ចុប្បន្ន កិច្ចការទាំងនេះ គឺធ្វើចំពោះអ្នកស្មោះស្ម័គ្រ ដែលយើងសូមសំដែងកតវេទិធម៌ក្នុងទីនេះ ។ តែមានថ្ងៃណាមួយក្នុងកាលជាអនាគតប្រហែលជាថ្ងៃនោះជិតដល់ហើយ ដែលយើងត្រូវការអគ្គលេខាធិការអាចិន្ត្រៃម្នាក់ ។ ម្យ៉ាងវិញទៀត, យើងត្រូវការមូលនិធិ, ខ្ញុំសូមរំឭកលោកអ្នកកុំភ្លេចនូវបញ្ហានេះសោះឡើយ ។ (មានត)

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៨៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យួន-យិម នាមឆាយា សុវណ្ណជោត កើតឆ្នាំច អាយុ ៤១ វស្សា ២០ ជាចៅអធិការ វត្តអង្គរកា ឃុំបឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៨៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ណុប នាមឆាយា ព្រហ្មជោត កើតឆ្នាំខាល អាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួន-ទ្រី នាមឆាយា ព្រហ្មជោត កើតឆ្នាំជូត អាយុ ៤៦ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉េប-នៅ នាមឆាយា គ្មាន ... កើតឆ្នាំរកា អាយុ ៤០ វស្សា ២០ ជាចៅអធិការ វត្តមៀន ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៨៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សឿ-យិម នាមឆាយា មង្គលសត្ថា កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្តត្រពាំងព្រះ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៩១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ាង-លាង នាមងារ សុវណ្ណបញ្ញាកេសរ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្តឃ្លាយ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៩២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កៀក-ម៉ុម នាមងារ ឥន្ទកេសរ កើតឆ្នាំមមី អាយុ ៤៤ វស្សា ២៤ ជាចៅអធិការវត្តទំពស្តេច ឃុំងាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៨៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់-លួន នាមងារ ឥន្ទកេសរ កើតឆ្នាំរក អាយុ ៤២ វស្សា ២២ ជាចៅអធិការវត្តតក្សាកម ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៨៩៧ ចុះថ្ងៃពុធ ៩ កើតខែបុស្ស ឆ្នាំជូតឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ឡុង-បាន នាមងារ សុវណ្ណជោត កើតឆ្នាំរោង អាយុ ៤៦ វស្សា ២៦ ជាចៅអធិការ វត្តកែវព្រះភ្លើង ឃុំលេខ ៦ ក្រុងភ្នំពេញ ក្រុមមៀង ។

សញ្ញាប័ត្រលេខ ៩១០ ចុះថ្ងៃសុក្រ ៩ កើតខែមាឃ ឆ្នាំជូតឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ប៉ាក់-ផង់ នាមងារ ធម្មសរ កើតឆ្នាំខាល អាយុ ៦០ វស្សា ៤១ ជាចៅអធិការ វត្តព្រៃអារ ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ។

(មានត)

ការដែលពុទ្ធសាសនបណ្ឌិត្យ សុំឲ្យអស់លោក-អ្នកបង់តម្លៃជាវជាមុនដូច្នេះ ប្រយោជន៍នឹងចាត់ការរៀបចំបញ្ញើសៀវភៅទាំងនោះមកប្រគេន-ជូនឲ្យបានរហ័សឆាប់ផង ប្រយោជន៍នឹងលៃលកកំណត់ចំនួនសៀវភៅដែលត្រូវបោះពុម្ពក្នុងមួយភាគៗ កុំឲ្យខ្វះខាតផង ព្រោះអស់លោក អ្នកគង់ជ្រាបស្រាប់ហើយថា ការខ្វះខាតសៀវភៅភាគទីមួយៗតទៅថ្ងៃមុខនោះ មិនងាយនឹងសើរើបោះពុម្ពបំពេញឡើងវិញ សម្រាប់ជាវប្រគេន-ជូនឲ្យបានទាន់ចិត្តឆាប់ភ្លាមៗទេ ។

ភ្នំពេញ, ថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៥៣

ពុទ្ធសាសនបណ្ឌិត្យ